EAC

## អាជ្ញាធរអគ្គិសនីកម្ពុជា
## ELECTRICITY AUTHORITY OF CAMBODIA

## ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
## ELECTRICITY LAW OF THE KINGDOM OF CAMBODIA

# សេចក្តីសម្រេចកែសម្រួលលើកទី៧
# លើឯកសារអាជ្ញាបណ្ណលេខ ០៩០ ឯអ ចុះថ្ងៃទី១៦ ខែមីនា
# ឆ្នាំ២០០៤ សម្រាប់ក្រុមហ៊ុន វាសនា ញូលែន ផៅវ័រ
# ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ
# និងផ្នែកខ្លះនៃស្រុកមុខកំពូល និងស្រុកពញាឮ ខេត្តកណ្តាល

## សម្រាប់ការប្តូរប្រភេទអាជ្ញាបណ្ណពីអាជ្ញាបណ្ណរួម
## មកអាជ្ញាបណ្ណចែកចាយ

# DECISION ON THE SEVENTH REVISION

TO THE LICENSE DOCUMENT No.090 LD DATED MARCH 16, 2004 OF VEASNA NEW LAND POWER CO., LTD FOR PROVIDING ELECTRIC POWER SERVICE AT SOME PART OF KHAN CHROUY CHANGVA, PHNOM PENH AND SOME PART OF MUKKAMPOUL AND PONHEALEU DISTRICTS, KANDAL PROVINCE

**FOR CHANGING THE TYPE OF LICENSE**

**FROM CONSOLIDATED LICENSE TO DISTRIBUTION LICENSE**

**ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦**

**JUNE 15, 2016**

ព្រះរាជាណាចក្រកម្ពុជា

KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ

NATION RELIGION KING

អាជ្ញាធរអគ្គិសនីកម្ពុជា

ELECTRICITY AUTHORITY OF CAMBODIA

លេខ ៖ ៣៦១ សរ -១៦ អអក

# សេចក្តីសម្រេចកែសម្រួលលើកទី៧ លើឯកសារអាជ្ញាបណ្ណលេខ ០៩០ ឯអ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤ សម្រាប់ក្រុមហ៊ុន វាសនា ញូលែន ផៅវ័រ

# DECISION ON THE SEVENTH REVISION TO THE LICENSE DOCUMENT No.090 LD DATED MARCH 16, 2004 FOR VEASNA NEW LAND POWER CO., LTD

## អាជ្ញាធរអគ្គិសនីកម្ពុជា

## ELECTRICITY AUTHORITY OF CAMBODIA

- អនុវត្តតាមមាត្រា ៧ និង ៣៤ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

- In exercise of the powers conferred by Article 7 and 34 of the Electricity Law promulgated by the Royal Decree No. NS/RKM/0201/03, dated February 02, 2001.

-យោងឯកសារអាជ្ញាបណ្ណលេខ ០៩០ ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញឲ្យក្រុមហ៊ុន វាសនា ញូលែន ផៅវ័រ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤

-In accordance with License Document of Veasna New Land Power Co., Ltd No. 090 LD issued by Electricity Authority of Cambodia dated March 16, 2004.

-យោងកិច្ចព្រមព្រៀងលក់-ទិញអគ្គិសនីរវាង អគ្គិសនីកម្ពុជា និងក្រុមហ៊ុន វាសនា ញូលែន ផៅវ័រ ដែលបានចុះហត្ថលេខានៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១០

-In accordance with the Power Purchase Agreement (PPA) between Electricite du Cambodge (EDC) and Veasna New Land Power Co., Ltd signed on February 24, 2010.

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៥ ដល់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៥

-In accordance with the consultation with concerned parties and public, made from January 13, 2015 to February 15, 2015.

-យោងតាមការអនុម័តរបស់សម័យប្រជុំរបស់ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី ២៩៦ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦

- In accordance with the decision of Electricity Authority of Cambodia's Session No. 296 dated June 15, 2016.

## សម្រេច

## DECIDES

| | |
|---|---|
| **ប្រការ១**<br>កែសម្រួលឯកសារអាជ្ញាបណ្ណលេខ ០៩០ ឯអ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤ ដែលបានផ្តល់ជូន**ក្រុមហ៊ុន វាសនា ញូលែន ផៅវ័រ** (បន្ទាប់ពីនេះទៅហៅថា "**អ្នកកាន់អាជ្ញាបណ្ណ**") ដោយប្តូរប្រភេទអាជ្ញាបណ្ណពីអាជ្ញាបណ្ណរួម ដែលរួមមានអាជ្ញាបណ្ណផលិតកម្ម និងអាជ្ញាបណ្ណចែកចាយ មកជាអាជ្ញាបណ្ណចែកចាយ សម្រាប់ធ្វើសេវាកម្មចែកចាយអគ្គិសនីក្នុងតំបន់អនុញ្ញាត ដែលកំណត់ក្នុងឧបសម្ព័ន្ធទី១ ដោយទិញអគ្គិសនីពី**អគ្គិសនីកម្ពុជា** ក្នុងក្របខណ្ឌនៃកិច្ចព្រមព្រៀងលក់-ទិញអគ្គិសនីរវាងអគ្គិសនីកម្ពុជា និងក្រុមហ៊ុន វាសនា ញូលែន ផៅវ័រ ដែលបានចុះហត្ថលេខានៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១០ ។ | **Article 1**<br>To revise the License Document No. 090 LD dated March 16, 2004 which was issued to **Veasna New Land Power Co., Ltd** (hereinafter referred to as "**Licensee**") for changing the type of license from Consolidated License consisting of Generation License and Distribution License to Distribution License, for granting the right to licensee to distribute electricity in authorized distribution area is determined in schedule 1, by purchasing electricity from **Electricite du Cambodge (EDC)** under the Power Purchase Agreement (PPA) between EDC and Veasna New Land Power Co., Ltd signed on February 24, 2010. |
| សិទ្ធិខាងលើ ត្រូវអនុលោមទៅតាមលក្ខខណ្ឌនានារបស់អាជ្ញាបណ្ណដែលមានចែងក្នុងផ្នែកទី២ កែសម្រួលថ្មី របស់អាជ្ញាបណ្ណនេះ ។ | The above right shall be in accordance with condition of license specified in the new revised part 2 of license. |
| **ប្រការ២**<br>ប្រការ១(ក) ក្នុងផ្នែកទី១ និងឧបសម្ព័ន្ធទី២ នៃឯកសារអាជ្ញាបណ្ណលេខ ០៩០ ឯអ ត្រូវបានលុបចេញពីឯកសារអាជ្ញាបណ្ណលេខ ០៩០ ឯអ ។ | **Article 2**<br>Article 1 (a) of Part I and Schedule 2 of the license documents No. 090 LD is deleted. |
| **ប្រការ៣**<br>ខ្លឹមសារផ្នែកទី២ នៃឯកសារអាជ្ញាបណ្ណលេខ ០៩០ ឯអ ត្រូវជំនួសដោយខ្លឹមសារផ្នែកទី២ កែសម្រួលថ្មីដូចមានភ្ជាប់មកជាមួយ ។ | **Article 3**<br>Part II of the license document No. 090 LD is replaced by the new revised Part II attached herewith. |
| **ប្រការ៤**<br>ខ្លឹមសារដទៃទៀតនៃឯកសារអាជ្ញាបណ្ណលេខ ០៩០ ឯអ ត្រូវស្ថិតនៅជាធរមានដដែល ។ | **Article 4**<br>The other contents of the license document No. 090 LD shall remain in force. |
| **ប្រការ៥**<br>សេចក្តីសម្រេចនេះ ត្រូវចាត់ទុកជាផ្នែកមួយនៃឯកសារអាជ្ញាបណ្ណលេខ ០៩០ ឯអ ។ | **Article 5**<br>This decision shall be considered as a part of the license document No. 090 LD. |
| **ប្រការ៦**<br>សេចក្តីសម្រេចនេះ ត្រូវចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ | **Article 6**<br>This decision shall come into force from the date of signing. |
| **ប្រការ៧**<br>អ្នកកាន់អាជ្ញាបណ្ណ ត្រូវផ្ញើសេចក្តីសម្រេចនេះទៅតម្កល់ទុកបន្ថែមនៅតាមទីកន្លែងដែលឯកសារអាជ្ញាបណ្ណលេខ ០៩០ ឯអ បានតម្កល់ទុកពីមុន ដើម្បីឲ្យឯកសារអាជ្ញាបណ្ណលេខ ០៩០ ឯអ ដែលតម្កល់ទុកមានការកែសម្រួលជាថ្មីស្របតាមសេចក្តីសម្រេចនេះ ។ | **Article 7**<br>The licensee shall send this decision to deposit additionally at the places, where the license document No. 090 LD has been deposited in order that the deposited license document No. 090 LD is in conformity with this decision. |

ភ្នំពេញ, ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦

Phnom Penh, June 15, 2016

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

CHAIRMAN OF ELECTRICITY AUTHORITY OF CAMBODIA

**បណ្ឌិត.ធី នរិន្ទ**

# ផ្នែកទី២

# លក្ខខណ្ឌរបស់អាជ្ញាបណ្ណ

## ធ្វើការកែសម្រួលជាថ្មីក្នុងសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា លើកទី ២៩៦ នាថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦

# PART II

# CONDITIONS OF LICENSE

## AS AMENDED IN SESSION OF EAC No. 296 DATED JUNE 15, 2016

# តារាងមាតិកា
# TABLE OF CONTENTS


| | |
|---|---|
| **១-និយមន័យរបស់ពាក្យប្រើក្នុងអាជ្ញាបណ្ណ** | **1-Definitions of terms used in the license** |
| **២-ភាតព្វកិច្ចទូទៅរបស់អ្នកកាន់អាជ្ញាបណ្ណ** | **2-General Obligation of licensee** |
| **លក្ខខណ្ឌទី១៖** កាតព្វកិច្ចគោរពច្បាប់ និងអនុក្រឹត្យ | **Condition 1:** Obligation on compliance with the Law and Sub-decree |
| **លក្ខខណ្ឌទី២៖** កាតព្វកិច្ចគោរពតាមស្តង់ដាបច្ចេកទេស សុវត្ថិភាព និងបរិស្ថាន | **Condition 2:** Obligation on compliance with technical standard, safety and environment |
| **លក្ខខណ្ឌទី៣៖** កាតព្វកិច្ចគោរពតាមបទបញ្ជា ឬ សេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការដាក់វិធាន និងបទប្បញ្ញត្តិនានាសម្រាប់ការធ្វើសេវាកម្មចែកចាយ | **Condition 3:** Obligation on compliance with EAC's order in issuing rules and regulations for distribution service |
| **លក្ខខណ្ឌទី៤៖** កាតព្វកិច្ចគោរពតាមលក្ខខណ្ឌសេវាកម្មដែលកំណត់ក្នុងអាជ្ញាបណ្ណរបស់ខ្លួន | **Condition 4:** Obligation on compliance with conditions of electric power service specified in its license |
| **លក្ខខណ្ឌទី៥៖** កាតព្វកិច្ចធ្វើរបាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍សកម្មភាពសេវាកម្មរបស់ខ្លួនតាមការកំណត់របស់អាជ្ញាធរអគ្គិសនីកម្ពុជា | **Condition 5:** Obligation on Financial statement and its electric power service report in accordance with EAC's adoption |
| **លក្ខខណ្ឌទី៦៖** កាតព្វកិច្ចបង់កម្រៃអាជ្ញាបណ្ណ | **Condition 6:** Obligation on payment of license fee |
| **៣-លក្ខខណ្ឌសេវាកម្ម** | **3-SERVICE CONDITIONS** |
| **លក្ខខណ្ឌទី៧៖** លក្ខខណ្ឌចំពោះតំបន់ធ្វើសេវាកម្ម | **Condition 7:** Condition on electric power service area |
| **លក្ខខណ្ឌទី៨៖** លក្ខខណ្ឌចំពោះមធ្យោបាយធ្វើសេវាកម្ម | **Condition 8:** Condition on electric power service utilities |
| **លក្ខខណ្ឌទី៩៖** លក្ខខណ្ឌចំពោះកិច្ចដំណើរការប្រព័ន្ធចែកចាយ | **Condition 9:** Condition on distribution system operation |
| **លក្ខខណ្ឌទី១០៖** លក្ខខណ្ឌចំពោះការធ្វើអាជីវកម្មអគ្គិសនី | **Condition 10:** Condition on electric power business |
| **លក្ខខណ្ឌទី១១៖** លក្ខខណ្ឌចំពោះការផ្គត់ផ្គង់អគ្គិសនីឲ្យអតិថិជន | **Condition 11:** Condition on electric power supply to customers |
| **លក្ខខណ្ឌទី១២៖** លក្ខខណ្ឌពាក់ព័ន្ធនឹងផលប្រយោជន៍សាធារណៈ | **Condition 12:** Condition on public interest |
| **លក្ខខណ្ឌទី១៣៖** ការទំនាក់ទំនង | **Condition 13:** Communication |
| **លក្ខខណ្ឌទី១៤៖** លក្ខខណ្ឌលក់មធ្យោបាយចែកចាយ ក្នុងករណីមានការតម្រូវពីអាជ្ញាធរអគ្គិសនីកម្ពុជា | **Condition 14:** Sale Condition of distribution facility in the case it is required from EAC |
| **ឧបសម្ព័ន្ធទី១៖** តំបន់អនុញ្ញាតឲ្យចែកចាយអគ្គិសនី | **Schedule 1:** Authorized distributing area |
| **ឧបសម្ព័ន្ធទី៣៖** លក្ខខណ្ឌសម្រាប់ធ្វើការដកហូតអាជ្ញាបណ្ណ | **Schedule 3:** Term of revocation |

# លក្ខខណ្ឌនៃអាជ្ញាបណ្ណ
# CONDITIONS OF LICENSE

| | | | |
|---|---|---|---|
| **១-និយមន័យរបស់ពាក្យប្រើក្នុងអាជ្ញាបណ្ណ** | | **1-DEFINITIONS OF TERMS USED IN THE LICENSE** | |
| ពាក្យពេចន៍ទាំងឡាយណាដែលបានប្រើប្រាស់ក្នុងឯកសារអាជ្ញាបណ្ណនេះ ឬ ផ្នែកណាមួយរបស់ឯកសារនេះ និងនៅក្នុងឧបសម្ព័ន្ធភ្ជាប់ប្រសិនបើពុំមានការបញ្ជាក់ខ្លឹមសារផ្សេងទេ ត្រូវមានន័យដូចខាងក្រោម ៖ | | In this or any of the following Parts of this document and in the Schedules below, unless otherwise specified or the context otherwise requires: | |
| "សវនកម្ម" | មានន័យថា ការជំរះបញ្ជីលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកកាន់អាជ្ញាបណ្ណដោយសវនករមួយ ក្នុងពេលធ្វើអាជីវកម្ម ។ | "Audit" | means audit on the licensee's financial statement of financial year by an auditor. |
| "លក្ខខណ្ឌ" | មានន័យថាលក្ខខណ្ឌចែងក្នុងអាជ្ញាបណ្ណនេះ ។ | "Condition" | means a Condition set out in this License. |
| "ថ្លៃភ្ជាប់ប្រព័ន្ធ" | មានន័យថា បន្ទុកត្រូវបង់ថ្លៃចំណាយសម្រាប់ការអនុវត្តនការងារ ការផ្តល់សំភារៈ និងការតំឡើងនៃបរិក្ខារអគ្គិសនីខ្សែបណ្តាញអគ្គិសនី និងនាឡិកាស្ទង់ផ្ទៃក្នុង ក្នុងការសាងសង់ ឬ ការកែសម្រួលចំណុចដែលត្រូវភ្ជាប់ចូល និងភ្ជាប់ចេញនៃប្រព័ន្ធចែកចាយអគ្គិសនី របស់អ្នកកាន់អាជ្ញាបណ្ណ ។ | "Connection charges" | means charges made for carrying out works and provision and installation of electrical plant, electric lines and meters in constructing or modifying entry and exit points on the Licensee's Distribution System to give supply to a consumer. |
| "អ្នកប្រើប្រាស់" | មានន័យថា បុគ្គលណាមួយ ឬ អ្នកទទួលសិទ្ធិបន្តដែលទិញឬ ទទួលអគ្គិសនីដើម្បីប្រើប្រាស់ និងមិនមែនដើម្បីផ្តល់ ឬ លក់បន្តឲ្យអ្នកដទៃទៀតឡើយ។ | "Consumer" | means a person or his authorized representative that purchases or receives electricity for consumption and not for delivery or resale to others. |
| "អ្នកប្រើប្រាស់ធុនតូច" | គឺអ្នកប្រើប្រាស់ ដែលទទួលការផ្គត់ផ្គង់ពីខ្សែបណ្តាញសាធារណៈតង់ស្យុងទាប ២៣០វ៉ុល ១ហ្វា និងត្រូវការកម្លាំងរហូតដល់ ៦០អំពែរ ឬ ៤០០វ៉ុល ៣ហ្វា និងត្រូវការកម្លាំងរហូតដល់ ៩០អំពែរ ។ | "Small Consumers" | mean a consumer requiring power up to 60 amperes at single phase 230 volts or up to 90 amperes at three phase 400 volts is categorized as Small Consumer. Small Consumers will be supplied power from the public LV network. |
| "អ្នកប្រើប្រាស់ធុនមធ្យម" | គឺអ្នកប្រើប្រាស់ ដែលទទួលការផ្គត់ផ្គង់ពីបន្ទប់ភ្លើង MV/LV តាមទ្វារចេញតង់ស្យុងទាបដាច់ដោយឡែក ៤០០វ៉ុល ៣ហ្វា និងមានកម្លាំងលើសពី ៩០អំពែរ រហូតដល់តិចជាង ១៥០អំពែរ។ នាឡិកាស្ទង់ ត្រូវតម្លើងនៅលើទ្វារចេញនៅក្នុងបន្ទប់ភ្លើងនោះ។ | "Medium Consumers" | mean a consumer requiring power more than 90 amperes and less than 150 amperes at three phase 400 volts is categorized as Medium Consumer. Medium Consumers will be supplied power through a separate LV feeder from the MV/LV substation. The meter will be installed at the substation on this feeder. |
| "អ្នកប្រើប្រាស់ធុនធំ" | គឺអ្នកប្រើប្រាស់ដែលទទួលការផ្គត់ផ្គង់ជាទូទៅពីបន្ទប់ភ្លើង MV/LV ដាច់ដោយឡែកនៅក្នុងទីតាំងរបស់អ្នកប្រើប្រាស់តាមតង់ស្យុង ៤០០វ៉ុល ៣ហ្វារ និងត្រូវការកម្លាំងលើសពី ១៥០អំពែរ រហូតដល់ តិចជាង ៤០០អំពែរ ។ ក្នុងករណីខ្លះ បើអ្នកផ្គត់ផ្គង់ ពិនិត្យឃើញថាអាចអនុវត្តបានសម្រាប់អ្នកប្រើប្រាស់ ដែលប្រើប្រាស់អនុភាពមួយផ្នែកនៃបន្ទប់ភ្លើង ការផ្គត់ផ្គង់អាចបន្តចេញតាមខ្សែតង់ស្យុងទាបដាច់ដោយឡែកពីបន្ទប់ភ្លើងសាធារណៈ ។ នាឡិកាស្ទង់ត្រូវតម្លើង | "Big Consumers" | mean a consumer requiring power more than 150 amperes and less than 400 amperes at three phase 400 volts is categorized as Big Consumer. Big Consumers will be supplied power generally from a separate MV/LV substation on their premises. The meter will be installed indoors or close to the substation. In some cases, if found |

| | | | |
|---|---|---|---|
| | នៅលើទ្វារចរន្ត នៅបន្ទប់ភ្លើងនោះ ។ | | feasible by the licensee, the supply to Big Consumers can be given by partly utilizing the capacity of a public MV/LV substation through a separate LV feeder. The meter will be installed at the substation on this feeder. |
| "អ្នកប្រើប្រាស់តង់ស្យុងមធ្យម" | គឺអ្នកប្រើប្រាស់ដែលទទួលការផ្គត់ផ្គង់អគ្គិសនីតង់ស្យុងមធ្យមពីបណ្តាញតង់ស្យុងមធ្យម និងមានតម្រូវការអនុភាពមិនតិចជាង 275kVA ។ នាឡិកាស្ទង់តង់ស្យុងមធ្យម ត្រូវតម្លើងនៅលើបណ្តាញតង់ស្យុងមធ្យមផ្ទាល់។ | "MV Consumers" | mean a consumer requiring power more than 275kVA will be supplied power at MV by a direct connection from the MV network. MV metering will be provided on the MV connection. |
| "អ្នកប្រើប្រាស់ធំ" | គឺអ្នកប្រើប្រាស់ទាំងឡាយណា ដែលទទួលការផ្គត់ផ្គង់អគ្គិសនីតាមតង់ស្យុងខ្ពស់(លើសពី ៣៥ ០០០ វ៉ុល)។ | "Bulk Consumers" | are consumers supplied power at high voltage (above 35 000 Volts). |
| "អតិថិជន" | មានន័យថា បុគ្គលណាមួយដែលបានទទួលការផ្គត់ផ្គង់ ឬ ទាមទារឲ្យមានការផ្គត់ផ្គង់អគ្គិសនីឲ្យទីតាំងខ្លួនក្នុងតំបន់អនុញ្ញាត ។ | "Customer" | means any person supplied or requiring to be supplied with electricity either for own consumption or for delivery or sales to others. |
| "អាជីវកម្មចែកចាយ" | មានន័យថាការធ្វើអាជីវកម្មរបស់អ្នកកាន់អាជ្ញាបណ្ណចែកចាយមានលក្ខណៈជា ៖<br>(ក)-ការចែកចាយអគ្គិសនី តាមរយៈប្រព័ន្ធចែកចាយរបស់អ្នកកាន់អាជ្ញាបណ្ណគិតរួមទាំងអាជីវកម្មក្នុងការផ្គត់ផ្គង់ការតភ្ជាប់ប្រព័ន្ធជាមួយ ប្រព័ន្ធនេះ<br>(ខ)-ការផ្តល់សេវាសម្រាប់នាឡិកាស្ទង់ និង<br>(គ)-ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់ ។ | "Distribution Business" | means the business of the Distribution Licensee including a business ancillary to:<br>(a) the distribution of electricity through the Licensee's Distribution System, including any business in providing connections to such system;<br>(b) the provision of Metering Services; and<br>(c) the supply of electricity to consumers. |
| "កូដប្រព័ន្ធចែកចាយ" | ជាក្បួនច្បាប់ដែលគ្របដណ្តប់លើទិដ្ឋភាពបច្ចេកទេសធំៗទាំងអស់ដែលពាក់ព័ន្ធជាមួយការតភ្ជាប់ការ ដំណើរការ និងការប្រើប្រាស់ប្រព័ន្ធចែកចាយរបស់អ្នកកាន់អាជ្ញាបណ្ណ ឬ ការដំណើរការខ្សែបណ្តាញ និងបរិក្ខារអគ្គិសនី ដែលបានតភ្ជាប់ជាមួយប្រព័ន្ធចែកចាយរបស់អ្នកកាន់អាជ្ញាបណ្ណ ឬ របស់បុគ្គលណាមួយផ្សេងទៀត ដែលបានទទួលការអនុញ្ញាតឲ្យតភ្ជាប់ជាមួយប្រព័ន្ធរបស់អ្នកកាន់អាជ្ញាបណ្ណ ។ | "Distribution Code" | means the Distribution Code covering all material technical aspects relating to connections to and the operation and use of the Licensee's Distribution System and the operation of electric lines and electrical plant connected to the Distribution System of the Licensee or distribution system of any other person authorized to connect with Licensee's system. |
| "អាជ្ញាបណ្ណចែកចាយ" | មានន័យថា អាជ្ញាបណ្ណចែកចាយដែលបានផ្តល់ក្នុងប្រការ១ នៃផ្នែកទី១ ។ | "Distribution License" | means the Distribution License granted in Article 1 of Part I. |
| "ប្រព័ន្ធចែកចាយ" | មានន័យថា ខ្សែបណ្តាញអគ្គិសនីទាំងអស់របស់អ្នកកាន់អាជ្ញាបណ្ណក្នុងតំបន់ចែកចាយដែលបានអនុញ្ញាត និងខ្សែបណ្តាញអគ្គិសនីណាមួយផ្សេងទៀត ដែលអាជ្ញាធរអគ្គិសនីកម្ពុជាអាចបញ្ជាក់ថា ជាផ្នែកនៃប្រព័ន្ធចែកចាយរបស់អ្នកកាន់អាជ្ញាបណ្ណព្រមទាំងនាឡិកាស្ទង់ និងបរិក្ខាអគ្គិសនីណាមួយរបស់អ្នកកាន់អាជ្ញាបណ្ណ | "Distribution System" | Means all electric lines of the Licensee within the Licensee's authorized distribution area and any other electric lines which EAC may specify as forming part of the Licensee's Distribution System, and includes any |

| | | | |
|---|---|---|---|
| | ដែលបានប្រើប្រាស់សម្រាប់ចែកចាយអគ្គិសនី ដោយអ្នកកាន់អាជ្ញាប័ណ្ណ ដោយឡែកចំពោះអ្នកចែកចាយដ៏ទៃណាមួយផ្សេងទៀត វាមានអត្ថន័យដូចគ្នាដូចមានចែងក្នុងអាជ្ញាប័ណ្ណ ដែលបានកាន់ដោយអ្នកកាន់អាជ្ញាប័ណ្ណចែកចាយនោះ ។ | | electrical plant and meters of the Licensee which are used in connection with the distribution of electricity by the Licensee; and, in relation to any other distributor, it shall have the same meaning as it has in the license held by such distributor. |
| "អ្នកចែកចាយ" | មានន័យថាបុគ្គលណាមួយដែលបានកាន់អាជ្ញាប័ណ្ណចែកចាយ ។ | "Distributor" | means any person who holds a Distribution License. |
| "អាជ្ញាធរអគ្គិសនីកម្ពុជា" | មានន័យថា អាជ្ញាធរដែលបានបង្កើតឡើងដោយច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០២០១/០៣ ។ | "EAC" | means the Electricity Authority of Cambodia established by the Electricity Law promulgated by Royal Decree No. NS/RKM/0201/03. |
| "ឯកសារអាជ្ញាប័ណ្ណ" | មានន័យថា គឺជាឯកសារនេះដែលមានពីផ្នែកទី១ ដល់ផ្នែកទី២ និងឧបសម្ព័ន្ធទី១ ដល់ឧបសម្ព័ន្ធទី៣ ។ | "License Document" | means this document comprising Parts I, Part II and Schedules 1 to 3. |
| "អ្នកកាន់អាជ្ញាប័ណ្ណ" | មានន័យថា**ក្រុមហ៊ុន វាសនា ញូលែន ផៅវ័រ** ។ | "Licensee" | means **Veasna New Land Power Co., Ltd.** |
| "បរិក្ខានាឡិកាស្ទង់" | រួមមាននាឡិកាស្ទង់ និងបរិក្ខាពាក់ព័ន្ធដទៃទៀត ដែលមានឥទ្ធិពលផ្ទាល់លើការដំណើរការនាឡិកាស្ទង់នោះ ។ | "Metering equipment" | includes any meter and associated equipment, which materially affects the operation of that meter. |
| "ការជូនដំណឹង" | មានន័យថា (ប្រសិនបើពុំមានការបញ្ជាក់ផ្សេងទៀត) ការជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬដោយមធ្យោបាយសមស្របណាមួយផ្សេងទៀត ។ | "Notice" | means (unless otherwise specified) notice given in writing or by any other reasonable means. |
| "ការបញ្ជាក់" | រួមមាន ការបដិសេធ ឬការសំណូមពរណាមួយ ដែលបានធ្វើជាលាយលក្ខណ៍អក្សរ ។ | "Representation" | includes any objection or any other proposal made in writing. |

## ២ ភារកិច្ចទូទៅរបស់អ្នកកាន់អាជ្ញាប័ណ្ណ

## 2-GENERAL OBLIGATION OF LICENSEE

### លក្ខខណ្ឌទី១៖ ភារកិច្ចគោរពច្បាប់ និង អនុក្រឹត្យ

### Condition 1: Obligation on compliance with the Laws and Sub-Decrees

១- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវគោរពតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជាច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

1. The Licensee shall comply with the Electricity Law, other Laws and Sub Decrees relating to the Laws.

២- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវគោរពតាមភារកិច្ចបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/ ១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និងអនុក្រឹត្យនានា ពាក់ព័ន្ធនឹងការការពារបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា ។

2. The Licensee is subjected to the environmental obligations as specified in the Law on Environmental Protection promulgated by the Royal Decree NS/RKM/1296/36, dated 24/12/1996 and Other Sub-Decrees on Environmental Protection of the Kingdom of Cambodia

### លក្ខខណ្ឌទី២៖ ភារកិច្ចគោរពតាមស្តង់ដាបច្ចេកទេសសុវត្ថិភាព និងបរិស្ថាន

### Condition 2: Obligation on compliance with technical standard, Safety and Environment

១- អ្នកកាន់អាជ្ញាប័ណ្ណត្រូវគោរពតាមស្តង់ដា ទាក់ទងទៅនឹងកិច្ចប្រតិបត្តិការបច្ចេកទេស សុវត្ថិភាព និងបរិស្ថានដែលបង្កើតឡើង និងផ្សព្វផ្សាយដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

1. The Licensee shall comply with the standards on technical operation, safety and environment, issued and published by Ministry of Industry, Mines and Energy.

### លក្ខខណ្ឌទី៣៖ ភារកិច្ចគោរពបទបញ្ជា ឬ សេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ក្នុងការដាក់វិធាន និងបទប្បញ្ញត្តិនានាសម្រាប់ការធ្វើសេវាកម្មចែកចាយ

### Condition 3: Obligation on compliance with EAC's order in issuing rules and regulations for distribution service

| | |
|---|---|
| ១- អ្នកកាន់អាជ្ញាបណ្ណ ត្រូវគោរពតាមវិធានបទប្បញ្ញត្តិ និងនីតិវិធីនានា ដែលអាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចដាក់ឲ្យអនុវត្ត សម្រាប់ការធ្វើសេវាកម្មចែកចាយ ។ | 1. The Licensee shall comply with the provisions of the Rules, Regulations and Procedures on the electric distribution service issued by EAC. |
| ២- ក្នុងករណី និងក្នុងតំបន់ជាក់លាក់ណាមួយអាជ្ញាធរអគ្គិសនីកម្ពុជា (បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអ្នកកាន់អាជ្ញាបណ្ណ) អាចចេញលិខិតណែនាំបន្ធូរបន្ថយកាតព្វកិច្ចរបស់អ្នកកាន់អាជ្ញាបណ្ណតាមវាក្យខណ្ឌទី១ ចំពោះផ្នែកណាមួយនៃវិធាន, បទប្បញ្ញត្តិ ឬ នីតិវិធី និងតាមទំហំណាមួយដែលកំណត់ក្នុងលិខិតណែនាំ ។ | 2. In specific case and area, EAC may (following consultation with the Licensee) issue directions relieving the Licensee of its obligations under paragraph 1 in respect of such parts of the Rules, Regulations or Procedures and for such areas and for such period as specified in those directions. |
| **លក្ខខណ្ឌទី៤ ៖ កាតព្វកិច្ចគោរពលក្ខខណ្ឌសេវាកម្មដែលកំណត់ក្នុងអាជ្ញាបណ្ណរបស់ខ្លួន** | **Condition 4: Obligation on compliance with service conditions of license** |
| ១- អ្នកកាន់អាជ្ញាបណ្ណ ត្រូវគោរពតាមលក្ខខណ្ឌសេវាកម្មដែលកំណត់ក្នុងអាជ្ញាបណ្ណ ។ | 1. The Licensee shall comply with the provisions of service Condition stated in this license. |
| **លក្ខខណ្ឌទី៥ ៖ កាតព្វកិច្ចធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សកម្មភាពសេវាកម្មរបស់ខ្លួនតាមការកំណត់របស់អាជ្ញាធរអគ្គិសនីកម្ពុជា** | **Condition 5: Obligation on Financial statement and reports on electric power service required by EAC** |
| ១- ឆ្នាំការិយបរិច្ឆេទនៃអ្នកកាន់អាជ្ញាបណ្ណ ត្រូវចាប់គិតពីថ្ងៃទី១ ខែមករា រហូតដល់ថ្ងៃទី៣១ ខែធ្នូ រៀងរាល់ឆ្នាំ ។ | 1. The financial year of the Licensee shall be reckoned every year from 1st January to the following 31st December. |
| ២- អ្នកកាន់អាជ្ញាបណ្ណត្រូវផ្តល់ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា នូវច្បាប់ចំលងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចមិនលើសពី៣ខែ ក្រោយពីបញ្ចប់ឆ្នាំការិយបរិច្ឆេទដែលរបាយការណ៍នោះពាក់ព័ន្ធ ។ ការធ្វើសវនកម្មអាចជំនួសដោយការត្រួតពិនិត្យរបស់អាជ្ញាធរ ក្នុងករណីដែលសភាពការណ៍ជាក់ស្តែងតម្រូវ ។ | 2. The Licensee shall submit to EAC the copy of its audited financial statement not later than 3 months after the end of financial year to which they relate. The audit can be replaced by the control of EAC in the case that actual situation requires. |
| ៣- អ្នកកាន់អាជ្ញាបណ្ណ ត្រូវផ្តល់ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជានូវបណ្តាព័ត៌មានទាំងឡាយ ដែលអាជ្ញាធរទាមទារជាបន្តបន្ទាប់តាមបែបបទ និងទំរង់កំណត់ដោយអាជ្ញាធរ ដើម្បីអាចឲ្យអាជ្ញាធរផ្ទៀងផ្ទាត់មើលការអនុវត្តន៍របស់អ្នកកាន់អាជ្ញាបណ្ណតាមលក្ខខណ្ឌនៃអាជ្ញាបណ្ណនេះ និងតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងបទប្បញ្ញត្តិផ្សេងៗទៀត ។ | 3. The Licensee shall provide, in the manner and form and at time determined by EAC, such information as EAC may require from time to time for monitoring the Licensee's compliance with the conditions of this license, provisions of the electricity law and any other legislative or regulatory requirements. |
| ៤- ដោយមិនគិតពីភាពទូទៅនៃវាក្យខ័ណ្ឌទី៣ អាជ្ញាធរអគ្គិសនីកម្ពុជា អាចទាមទារឲ្យអ្នកកាន់អាជ្ញាបណ្ណផ្តល់នូវព័ត៌មានណាមួយឲ្យមានលក្ខណៈលំអិតខ្លាំងជាង ឬ ខុសពីការផ្តល់ព័ត៌មានធម្មតាដល់អាជ្ញាធរអគ្គិសនីកម្ពុជា ។ | 4. Without prejudice to the generality of paragraph 3, EAC may require the Licensee to supply information which is more extensive than or differs from that required to be prepared and supplied to EAC. |
| **លក្ខខណ្ឌទី៦ ៖ កាតព្វកិច្ចបង់កម្រៃអាជ្ញាបណ្ណ** | **Condition 6: Obligation on payment of license fee** |
| ១- ចាប់ពីថ្ងៃចូលជាធរមានរហូតដល់ថ្ងៃបញ្ចប់អាណត្តិ នៃអាជ្ញាបណ្ណនេះ អ្នកកាន់អាជ្ញាបណ្ណត្រូវបង់ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជានូវ**"កម្រៃអាជ្ញាបណ្ណ"**ប្រចាំខែតាមអាត្រាកម្រៃអាជ្ញាបណ្ណ និងរូបមន្តគណនាកម្រៃអាជ្ញាបណ្ណដែលត្រូវកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជាសម្រាប់ឆ្នាំការិយបរិច្ឆេទនីមួយៗ ដោយអនុលោមតាមមាត្រា២៧ របស់ច្បាប់ស្តីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣នៃអនុក្រឹត្យស្តីពីការកំណត់កំរិតអតិបរមានៃកម្រៃអាជ្ញាបណ្ណ សម្រាប់អនុវត្តចំពោះអ្នកធ្វើសេវាកម្មអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ | 1. From the effective date to end of the term of license, the Licensee shall pay to EAC **"the monthly license fee"** which is calculated according to the rate of license fee and the formula determined by EAC for each financial years pursuant to Article 27 of the Law and Article 3 of Sub-Decree of the Royal Government of Cambodia fixing the maximum of License fee for the electric power services in the Kingdom of Cambodia. |
| ២- វិក្កយបត្រនៃកម្រៃអាជ្ញាបណ្ណប្រចាំខែ ត្រូវចាត់ទុកថាជំពាក់ និងត្រូវបង់ក្នុងរយៈពេល១៤ថ្ងៃ បន្ទាប់ពីថ្ងៃដែលអ្នកកាន់អាជ្ញាបណ្ណបានទទួលវិក្កយបត្រ ។ | 2. Each invoice of monthly license fee shall be due and payable within 14 days after the day on which Licensee receives it. |

| | |
|---|---|
| **៣-លក្ខខណ្ឌសេវាកម្ម** | **3-SERVICE CONDITIONS** |
| **លក្ខខណ្ឌទី៧៖ លក្ខខណ្ឌចំពោះតំបន់ធ្វើសេវាកម្ម** | **Condition 7: Conditions on electric power service area** |
| ១- អាជ្ញាបណ្ណនេះផ្តល់សិទ្ធិឲ្យអ្នកកាន់អាជ្ញាបណ្ណ សម្រាប់ធ្វើសេវាកម្មចែកចាយអគ្គិសនីក្នុងតំបន់អនុញ្ញាត ដែលកំណត់ព្រំដែនច្បាស់លាស់ដូចមានបង្ហាញក្នុងឧបសម្ព័ន្ធទី១ នៃអាជ្ញាបណ្ណនេះ ។ | 1. This license grants the right to the licensee to distribute electric power in the authorized distribution area is clearly indicated in schedule 1 of this license. |
| ២- អ្នកប្រើប្រាស់ធុនធំ និងអ្នកប្រើប្រាស់ដុំក្នុងតំបន់ចែកចាយខាងលើ អាចមានសិទ្ធិជ្រើសរើសប្រភពផ្គត់ផ្គង់ពីប្រព័ន្ធបញ្ជូនឬពីប្រព័ន្ធចែកចាយមេផ្សេងទៀតបាន បើសិនជាមានការយល់ព្រមពីអាជ្ញាធរអគ្គិសនីកម្ពុជា ។ | 2. Big consumers and bulk consumers in the distribution area indicated in schedule 1 may have the right to select other supply sources from the transmission line or distribution network of other licensees, if they obtain prior approval from EAC. |
| **លក្ខខណ្ឌទី៨៖ លក្ខខណ្ឌចំពោះមធ្យោបាយធ្វើសេវាកម្ម** | **Condition 8: Conditions on electric power service utilities** |
| ១- អ្នកកាន់អាជ្ញាបណ្ណ មានកាតព្វកិច្ចអភិវឌ្ឍន៍មធ្យោបាយធ្វើសេវាកម្មរបស់ខ្លួន ដើម្បីអាចផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់របស់ខ្លួនបាន និងប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព ។ អ្នកកាន់អាជ្ញាបណ្ណត្រូវធ្វើផែនការ និងអភិវឌ្ឍន៍ប្រព័ន្ធចែកចាយរបស់ខ្លួនទៅតាមលក្ខខណ្ឌទូទៅ នៃស្តង់ដាបច្ចេកទេសអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា ដែលរៀបចំ និងប្រកាសឲ្យប្រើដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ | 1. The licensee shall have the obligation to develop its distribution system in order to supply the electricity to its consumers with efficiency and security. The licensee shall plan and develop its distribution system in confirming with the General Requirement of Electric Power Technical Standards of the Kingdom of Cambodia issued by Ministry of Industry, Mines and Energy. |
| ២- អ្នកកាន់អាជ្ញាបណ្ណត្រូវពង្រីក និងកែលំអប្រព័ន្ធចែកចាយរបស់ខ្លួនតាមកម្មវិធីដែលបានការយល់ព្រមពីអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីធានាការផ្គត់ផ្គង់អគ្គិសនីដល់គ្រប់អ្នកប្រើប្រាស់ក្នុងតំបន់ ។ | 2. The Licensee shall extent and to improve its distribution network in accordance with its plan approved by EAC to ensure the electricity supply to all consumers in the area of distribution. |
| **លក្ខខណ្ឌទី៩ ៖ លក្ខខណ្ឌចំពោះកិច្ចដំណើរការប្រព័ន្ធចែកចាយ** | **Condition 9: Conditions on distribution system operation** |
| ១- អ្នកកាន់អាជ្ញាបណ្ណ ត្រូវដំណើរការការផ្គត់ផ្គង់ និងការចែកចាយរបស់ខ្លួនតាមស្តង់ដាប្រតិបត្តិមួយ ដែលកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា អនុលោមតាមមាត្រា៣ និង៧(ង) របស់ច្បាប់ស្តីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា ។ | 1. The Licensee shall conduct its Supply and Distribution Operation to meet the standards of performance determined by EAC pursuant to Article 3 and 7(e) of the Electricity Law of the Kingdom of Cambodia. |
| ២- អ្នកកាន់អាជ្ញាបណ្ណ ត្រូវរៀបចំឲ្យមានប្រភពអគ្គិសនីគ្រប់គ្រាន់មួយសម្រាប់ផ្គត់ផ្គង់ឲ្យអតិថិជនរបស់ខ្លួន ។ អ្នកកាន់អាជ្ញាបណ្ណត្រូវធានានូវលក្ខខណ្ឌដូចខាងក្រោម ៖ | 2. The Licensee shall make available sufficient electricity for supply to its consumers. Licensee shall ensure the following conditions: |
| (ក)- មិនត្រូវមានការកាត់ផ្តាច់លើសពីរយៈពេលស្តង់ដា ដែលបានអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា និង | (a) Supply will not be discontinued for more than the permissible time approved by EAC; and |
| (ខ)- តង់ស្យុង និងហ្វ្រេកង់អគ្គិសនី មិនត្រូវហួសពីកំរិតព្រំដែនដំណើរការជាធម្មតាដែលអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។ | (b) The voltage or frequency of electricity will not go beyond the operational limits approved by EAC. |
| ៣- អ្នកកាន់អាជ្ញាបណ្ណ ត្រូវគោរពតាមកូដប្រព័ន្ធចែកចាយមួយ ដែលអាជ្ញាធរអគ្គិសនីកម្ពុជានឹងកំណត់នៅពេលក្រោយ ។ | 3. The Licensee shall comply with the Distribution Code, when approved by EAC. |
| **លក្ខខណ្ឌទី១០ ៖ លក្ខខណ្ឌចំពោះការធ្វើអាជីវកម្មអគ្គិសនី** | **Condition 10: Condition on electric power business** |
| ១- អ្នកកាន់អាជ្ញាបណ្ណ ត្រូវដំណើរការ និងគ្រប់គ្រងសេវាកម្មអគ្គិសនី ដែលបានផ្តល់ដោយអាជ្ញាបណ្ណនេះឲ្យមានប្រសិទ្ធភាព គុណភាព និងតម្លាភាពដោយអនុលោមតាមលក្ខខណ្ឌកំណត់ក្នុងអាជ្ញាបណ្ណនេះ និងបទប្បញ្ញត្តិនានា ដែលអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។ | 1. The Licensee shall operate and manage the Services provided under this License in an efficient, qualitative and transparent manner in accordance with the requirement of this License and the regulations issued by EAC. |
| ២- វិវាទឬជម្លោះណារវាងអ្នកកាន់អាជ្ញាបណ្ណ និងភាគីទី៣ដែលទាក់ទងនឹង | 2. Any dispute or difference between Licensee and third |

| | |
|---|---|
| កិច្ចព្រមព្រៀងណាមួយក្នុងការទិញអគ្គិសនីជាមួយភាគីទី៣ត្រូវដោះស្រាយអនុលោមតាមបញ្ញត្តិក្នុងកិច្ចព្រមព្រៀងជាមួយភាគីនោះ ។ | party relating to any agreement for purchase of electricity from third party shall be settled according to the provision in that agreement. |
| ៣- អ្នកកាន់អាជ្ញាបណ្ណពុំត្រូវចុះកិច្ចព្រមព្រៀងជាមួយភាគីទី៣ ដើម្បីទិញអគ្គិសនីដោយគ្មានការអនុម័តជាមុនពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។ | 3. The Licensee shall not enter into arrangements with third party for purchase of electricity without prior approval of EAC. |
| ៤- អ្នកកាន់អាជ្ញាបណ្ណ មិនត្រូវប្រើប្រាស់អចលនទ្រព្យនៃអាជីវកម្មរបស់អាជ្ញាបណ្ណនេះសម្រាប់គោលបំណងអ្វីក្រៅពីអាជីវកម្មដែលបានអនុញ្ញាត ដូចកំណត់ក្នុងឯកសារនេះ ដោយពុំមានការអនុម័តជាមុនពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។ | 4. The Licensee shall not use the assets of this License's business for the purpose other than the business permitted in this document without prior approval of EAC. |
| ៥- អ្នកកាន់អាជ្ញាបណ្ណ មិនត្រូវទទួលយកឬចូលរួមជាមួយអាជីវកម្មបន្ថែមណាមួយទៀតទេរួមទាំងអាជីវកម្មផលិត បញ្ជូន ចែកចាយ ឬ លក់ថាមពល ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។ | 5. The Licensee shall not acquire any additional business, including the business of generating, transmitting, distribution or supply of energy, without the prior approval in writing of EAC. |
| ៦- នៅគ្រប់ពេលអ្នកកាន់អាជ្ញាបណ្ណមិនត្រូវប្រគល់អាជ្ញាបណ្ណ ឬ ផ្ទេរការកាន់កាប់របស់ខ្លួន ឬ ផ្នែកណាមួយរបស់វា ដោយលក់ បញ្ចាំ ជួល ប្តូរ ឬ ផ្សេងពីនេះ បើពុំមានកំណត់ក្នុងកិច្ចព្រមព្រៀងទិញអគ្គិសនី និងពុំមានការអនុម័តពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។ | 6. The Licensee shall not, at any time, assign his License or transfer his undertaking, or any part thereof, by sale, mortgage, lease, exchange or otherwise, unless specified in PPA and approved by EAC. |
| ៧- កិច្ចព្រមព្រៀងណាមួយពាក់ព័ន្ធជាមួយកិច្ចការ ដែលបានអធិប្បាយក្នុងវាក្យខ័ណ្ឌទី៣-៤-៥ និងទី៦ខាងលើ បើពុំមានការឯកភាពជាលាយលក្ខណ៍អក្សរជាមុនពីអាជ្ញាធរអគ្គិសនីកម្ពុជាទេ ត្រូវចាត់ទុកថាជា មោឃៈ និងត្រូវទុកជាការរំលោភលើលក្ខខណ្ឌនៃអាជ្ញាបណ្ណ ។ | 7. Any agreement relating to any transaction of the nature described above at paragraph 3, 4, 5 and 6, unless made with the prior written consent of EAC, shall be void and would constitute violation of Conditions of License. |
| ៨- អ្នកកាន់អាជ្ញាបណ្ណត្រូវអនុវត្តថ្លៃលក់អគ្គិសនី និងបន្ទុកផ្សេងៗ ដែលអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។ | 8. The Licensee shall implement the tariff and charge approved by EAC for the Licensee. |
| **លក្ខខណ្ឌទី១១៖ លក្ខខណ្ឌចំពោះការផ្គត់ផ្គង់អគ្គិសនីឲ្យអតិថិជន** | **Condition 11: Condition on electric power supply to customer** |
| ១- អ្នកកាន់អាជ្ញាបណ្ណ ត្រូវគោរពតាមបទប្បញ្ញត្តិរបស់អាជ្ញាធរអគ្គិសនីកម្ពុជាស្តីពីលក្ខខណ្ឌទូទៅក្នុងការផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ | 1. The Licensee shall comply with the EAC's Regulation on general conditions of supply of electricity in the Kingdom of Cambodia. |
| ២- ក្នុងការចែកចាយអគ្គិសនី អ្នកកាន់អាជ្ញាបណ្ណមិនត្រូវរើសអើងរវាងបុគ្គល ឬ ក្រុមបុគ្គលណាមួយជាមួយបុគ្គល ឬក្រុមបុគ្គលណាមួយទៀតឡើយ ។ | 2. In the provision of electricity, the Licensee shall not discriminate between persons or classes of person. |
| ៣- អ្នកកាន់អាជ្ញាបណ្ណ (និងធានាថាភ្នាក់ងាររបស់ខ្លួន) ត្រូវធ្វើសកម្មភាពយ៉ាងណាសមស្របដើម្បីការពារ និងទប់ទល់នឹង ៖<br>(ក)-ការលួចអគ្គិសនីនៅចំណុចផ្គត់ផ្គង់<br>(ខ)- ការធ្វើឲ្យខូចខាតបរិក្ខាអគ្គិសនី, ខ្សែបណ្តាញឬនាឡិកាស្ទង់ណាមួយដែលតាមរយៈវា អតិថិជនបានទទួលការផ្គត់ផ្គង់<br>(គ)-ការប៉ះពាល់ដល់នាឡិកាស្ទង់ណាមួយ ដែលតាមរយៈវាអតិថិជនបានទទួលការផ្គត់ផ្គង់ | 3. The Licensee shall (and shall ensure that its agents) take all reasonable steps to detect and prevent:<br>(a) the theft of electricity at the point of supply<br>(b) damage to any electrical plant, electric line or electricity meter through which the consumer is supplied; and<br>(c) Interference with any electricity meter through which such premises are supplied. |
| ៤- អ្នកកាន់អាជ្ញាបណ្ណ ត្រូវបញ្ចូលក្នុងបញ្ញត្តិនៃកិច្ចសន្យាផ្គត់ផ្គង់ជាមួយអតិថិជនថា អតិថិជនត្រូវផ្តល់ព័ត៌មានឲ្យបានឆាប់រហ័សតាមដែលអាចអនុវត្តទៅបានឲ្យអ្នកកាន់អាជ្ញាបណ្ណនូវឧប្បត្តិហេតុណាមួយ ដែលគេជឿជាក់ថា ៖ | 4. The Licensee shall include in the provisions of supply contract with the customer that the customer shall, as soon as is reasonably practicable and possible, inform the Licensee of any incident where it has reason to believe: |

| | |
|---|---|
| (ក)- មានការខូចខាតបរិក្ខាអគ្គិសនី ខ្សែបណ្តាញ ឬ នាឡិកាស្ទង់អគ្គិសនី ឬ | (a) there has been damage to electrical plant, electric line or meter; or |
| (ខ)- មានការប៉ះពាល់នាឡិកាស្ទង់ ដោយធ្វើឲ្យលំអៀងដល់ការកត់ត្រា ឬ ទប់ស្កាត់មិនឲ្យកត់ត្រាបរិមាណអគ្គិសនីដែលបានផ្គត់ផ្គង់ ។ | (b) There has been interference with the meter to alter its register or prevent it from duly registering the quantity of electricity supplied. |
| ៥- អ្នកកាន់អាជ្ញាបណ្ណត្រូវរៀបចំ និងដាក់ជូនអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីស្នើសុំការយល់ព្រមលើនីតិវិធីរបស់ខ្លួនសម្រាប់ដោះស្រាយពាក្យបណ្តឹងរបស់អតិថិជនចំពោះខ្លួន ។ | 5. The Licensee shall prepare and submit to EAC its procedure for handling complaint from customers for approval. |
| ៦- អ្នកកាន់អាជ្ញាបណ្ណ ត្រូវបង្កើតនិងដំណើរការនូវសេវាផ្តល់ព័ត៌មានមួយសម្រាប់ផ្តល់ព័ត៌មានឲ្យអតិថិជនណាមួយ ដែលចង់ដឹងពីព័ត៌មានការណែនាំ ឬ ការផ្តល់យោបល់ពីបញ្ហាណាមួយឬឧបត្តិហេតុណាមួយក្នុងសេវាកម្មចែកចាយអគ្គិសនីរបស់ខ្លួន ។ | 6. The Licensee shall establish and operate an information service for use by any customer for the purposes of receiving information, guidance or advice about any matter or incident in its distribution service. |
| **លក្ខខណ្ឌទី១២ ៖ លក្ខខណ្ឌពាក់ព័ន្ធនឹងផលប្រយោជន៍សាធារណៈ** | **Condition 12: Conditions on public interest** |
| ១- អ្នកកាន់អាជ្ញាបណ្ណ មិនត្រូវបោះបង់ចោល ឬ បដិសេធចោលការគ្រប់គ្រងដំណើរការលើអចលនទ្រព្យអាជីវកម្មណាមួយ មុនពេលមានការឯកភាពពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។ អចលនទ្រព្យអាជីវកម្មមានន័យថា គឺជាអចលនទ្រព្យណាមួយ ដែលនៅពេលនោះ ជាផ្នែកមួយនៃប្រព័ន្ធចែកចាយរបស់អ្នកកាន់អាជ្ញាបណ្ណមជ្ឈមណ្ឌលបញ្ជាណាមួយ ដែលប្រើប្រាស់ជាមួយប្រព័ន្ធចែកចាយនោះ និងសិទ្ធិកម្មសិទ្ធិ ឬ អត្ថប្រយោជន៍ណាមួយលើដី ដែលអចលនទ្រព្យនោះស្ថិតនៅ ។ | 1. The Licensee shall not dispose of or relinquish operational control over any relevant asset prior to the written consent from EAC. "Relevant asset" means any asset for the time being forming part of the Licensee's Distribution System, any control center for use in conjunction therewith and any right, title or interest in land upon which any of the foregoing is situated. |
| ២- អ្នកកាន់អាជ្ញាបណ្ណ ត្រូវផ្តល់ឲ្យអាជ្ញាធរនូវសំណើជាលាយលក្ខណ៍អក្សរស្តីពីគោលបំណងរបស់គេក្នុងការបោះបង់ចោល ឬ បដិសេធចោលការគ្រប់គ្រងដំណើរការលើអចលនទ្រព្យអាជីវកម្មណាមួយ ដោយភ្ជាប់ជាមួយព័ត៌មានបន្ថែមផ្សេងទៀតតាមដែលអាជ្ញាធរស្នើសុំពាក់ព័ន្ធ ជាមួយនឹងអចលនទ្រព្យនោះ ឬ កាលៈទេសៈនៃការលះបង់ ឬ បដិសេធចោលការគ្រប់គ្រងនេះ ឬ គោលបំណងនៃបុគ្គលណាមួយ ដែលចង់ទទួលយក ឬ ទទួលគ្រប់គ្រងដំណើរការលើអចលនទ្រព្យនោះ ។ | 2. The Licensee shall give to EAC written proposal of its intention to dispose of or relinquish operational control over any relevant asset, together with such further information as EAC may request relating to such asset or the circumstances of such intended disposal or relinquishment of control or to the intentions in regard thereto of the person proposing to acquire such asset or operational control over such asset. |
| ៣- អាជ្ញាធរអគ្គិសនីកម្ពុជា (បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអ្នកកាន់អាជ្ញាបណ្ណ) អាចយល់ព្រម ឬ មិនយល់ព្រមនូវសំណើនេះ ។ | 3. EAC may (following consultation with the Licensee) give consent or refuse consent to this proposal. |
| ៤- អ្នកកាន់អាជ្ញាបណ្ណ ត្រូវពិគ្រោះយោបល់ជាមួយតំណាងបុគ្គលិក កម្មកររបស់ខ្លួន ដើម្បីបង្កើតឲ្យមានយន្តការ ឬ វេទិកាជាប្រចាំមួយ ដើម្បីរួមគ្នាគិតគូរពីបញ្ហារួមពាក់ព័ន្ធនឹងសុខភាព និងសុវត្ថិភាពរបស់ពួកគេ ។ | 4. The Licensee shall consult with appropriate representatives of persons employed by it in order to establish and maintain an appropriate machinery or forum for the joint consideration of matters of mutual concern in respect of the health and safety of such persons. |
| **លក្ខខណ្ឌទី១៣ ៖ ការទំនាក់ទំនង** | **Condition 13: Communication** |
| ១- រាល់ទំនាក់ទំនងទាំងអស់ពាក់ព័ន្ធជាមួយអាជ្ញាបណ្ណនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយយកភាសាខ្មែរជាគោល ។ | 1. All communications relating to this License shall be written in Khmer as official. |
| **លក្ខខណ្ឌទី១៤៖ លក្ខខណ្ឌលក់មធ្យោបាយចែកចាយក្នុងករណីមានការតម្រូវពីអាជ្ញាធរអគ្គិសនីកម្ពុជា** | **Condition 14: Sale Condition of distribution facility in the case it is the required from EAC** |
| ១- ក្នុងរយៈពេល ៦ខែ បន្ទាប់ពីបានទទួលអាជ្ញាបណ្ណនេះ អ្នកកាន់អាជ្ញាបណ្ណត្រូវស្នើសុំអាជ្ញាធរអគ្គិសនីកម្ពុជាអនុម័ត និងចុះបញ្ជីអចលនទ្រព្យ សម្រាប់ធ្វើសេវាកម្មរបស់ខ្លួន ។ បញ្ជីនេះត្រូវបញ្ជាក់លម្អិតនៅឆ្នាំចាប់ផ្តើមដំណើរការអាជីវកម្ម និងតំលៃដើមនៃមធ្យោបាយធ្វើសេវាកម្មនីមួយៗ ។ បន្ទាប់ពីនោះ នៅរៀងរាល់ឆ្នាំមុនថ្ងៃទី១៥ ខែកុម្ភៈ អ្នកកាន់អាជ្ញាបណ្ណត្រូវស្នើសុំ | 1. Within six months after receiving this license, the licensee shall submit the list of its facilities for approval and registering at EAC as relevant asset. The list should also give details on year of commissioning and the original cost of each facility. Thereafter, for revision of the list of relevant |

| | |
|---|---|
| អាជ្ញាធរអគ្គិសនីកម្ពុជាកែសម្រួលបញ្ជីមធ្យោបាយធ្វើសេវាកម្មរបស់ខ្លួនដែលមានជាក់ស្តែង ដល់ថ្ងៃទី៣១ ខែធ្នូ កន្លងមក ។ បញ្ជីនេះត្រូវបង្ហាញនូវមធ្យោបាយធ្វើសេវាកម្មដែលមានពីដើមឆ្នាំ ដែលបានបន្ថែម ឬលុបចេញក្នុងឆ្នាំដោយមានបញ្ជាក់តំលៃមធ្យោបាយធ្វើសេវាកម្មនោះ និងមធ្យោបាយធ្វើសេវាកម្មដែលមាននៅចុងឆ្នាំ ។ | asset, the licensee shall submit to EAC by $15^{th}$ February each year, the list of its facilities as on $31^{st}$ December of the previous year. The list should indicate the facilities in the beginning of the year, additions made during the year with its cost, deletion made during the year with its original cost and facilities at the end of the year. |
| ២- ស្របតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យនានា ក្នុងករណីដកហូតអាជ្ញាបណ្ណអាជ្ញាធរអគ្គិសនីកម្ពុជាអាចតម្រូវឲ្យអ្នកកាន់អាជ្ញាបណ្ណលក់ឬ ផ្ទេរមធ្យោបាយធ្វើសេវាកម្មដែលបានចុះបញ្ជីនៅអាជ្ញាធរអគ្គិសនីកម្ពុជាឲ្យអ្នកបន្តវេនមួយផ្សេងទៀត តាមគោលការណ៍ ហិរញ្ញវត្ថុដែលកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។ | 2. Under Electricity Law and Sub-decrees, in the case of revocation of license, EAC can require licensee to sale or transfer its facilities registered with EAC as relevant asset to the successor in accordance with financial principle determined by EAC. |

អាជ្ញាធរអគ្គិសនីកម្ពុជា

**ELECTRICITY AUTHORITY OF CAMBODIA**

លេខ No : 090 L

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# អាជ្ញាបណ្ណ

## សម្រាប់ធ្វើសេវាកម្មអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា

# LICENSE

## FOR PROVIDING ELECTRIC POWER SERVICES IN CAMBODIA

អនុវត្តតាមច្បាប់ស្តីពីអគ្គិសនី និងយោងការអនុម័តក្នុងសម័យប្រជុំលើកទី ២៩៦ របស់អាជ្ញាធរអគ្គិសនីកម្ពុជានាថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦

In exercise of the powers conferred by Electricity Law and in accordance with the decision of EAC's Session No. 296 on June 15, 2016

សម្រេចផ្តល់ : **អាជ្ញាបណ្ណចែកចាយ**

Decided to issue: **Distribution License**

ជូនក្រុមហ៊ុន : **វាសនា ញូវឡែន ផៅវ័រ ដែលបានចុះបញ្ជីពាណិជ្ជកម្ម លេខ Co. 12111/08P ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៨**

To : **VESNA NEW LAND POWER CO., LTD registered under Business Law No. Co. 12111/08P, dated June 02, 2008**

ដើម្បីធ្វើសេវាកម្មចែកចាយអគ្គិសនីនៅផ្នែកខ្លះនៃខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ផ្នែកខ្លះនៃស្រុកមុខកំពូល និងស្រុកពញាឮ ខេត្តកណ្ដាល ក្នុងក្របខណ្ឌរបស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងស្របតាមខ្លឹមសារ និងលក្ខខណ្ឌដែលមានក្នុងឯកសារអាជ្ញាបណ្ណលេខ ០៩០ ឯអ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤ ។

for providing the Electric Power Distribution Service at some part of Khan Chrouy Changva , Phnom Penh, some part of Mukkanpoul and Ponhealeu Districts, Kandal Province under Electricity Law of the Kingdom of Cambodia in accordance with the context and conditions specified in License's Document No. 090 LD of March 16, 2004.

ភ្នំពេញ Phnom Penh, ថ្ងៃទី Day 15 ខែមិថុនា June ឆ្នាំ 2016

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

**CHAIRMAN**

បណ្ឌិត.ធី នរិន្ទ

# អាជ្ញាធរអគ្គិសនីកម្ពុជា
**ELECTRICITY AUTHORITY OF CAMBODIA**

# ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
**ELECTRICITY LAW OF THE KINGDOM OF CAMBODIA**

## សេចក្តីសម្រេចកែសម្រួលលើកទី៧
## លើឯកសារអាជ្ញាប័ណ្ណលេខ ០៩០ ឯអ ចុះថ្ងៃទី១៦ ខែមីនា ២០០៤ សម្រាប់ក្រុមហ៊ុន វាសនា ញូវលែន ផៅវ័រ ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ស្រុកមុខកំពូល ស្រុកពញាឮ ខេត្តកណ្តាល និងស្រុកបាធាយ ខេត្តកំពង់ចាម

## សម្រាប់ការបង្កើនអាណត្តិអាជ្ញាប័ណ្ណ
## និងការពង្រីកតំបន់ចែកចាយ

## DECISION ON THE SEVENTH REVISION

OF THE LICENSE DOCUMENT No. 090 LD DATED MARCH 16, 2004 FOR VEASNA NEW LAND POWER CO., Ltd FOR PROVIDING ELECTRIC POWER SERVICE AT SOME PART OF KHAN RUSSEY KEO, PHNOM PENH, MOKKAMPOUL, PONHEALEU DISTRICTS, KANDAL PROVINCE AND BATHEAY DISTRICT, KAMPONG CHAM PROVINCE

## FOR INCREASING TERM OF LICENSE
## AND EXTENDING DISTRIBUTION AREA

ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៤

**DECEMBER 09, 2014**

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរអគ្គិសនីកម្ពុជា
ELECTRICITY AUTHORITY OF CAMBODIA
លេខ ៖ ៣៧៦ សរ -១៤-អអក

# សេចក្តីសម្រេចកែសម្រួលលើកទី៧
# លើឯកសារអាជ្ញាប័ណ្ណលេខ ០៩០ ឯអ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤
# សម្រាប់ក្រុមហ៊ុន វាសនា ញូលែន ផៅវ័រ

# DECISION ON THE SEVENTH REVISION
# OF THE LICENSE DOCUMENT No. 090 LD DATED MARCH 16, 2004
# FOR VEASNA NEW LAND POWER CO., Ltd

## អាជ្ញាធរអគ្គិសនីកម្ពុជា
## ELECTRICITY AUTHORITY OF CAMBODIA

-អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស.រកម.០២០១.០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

-In exercise of the powers conferred by Article 7 and 35 of the Electricity Law promulgated by the Royal Decree No. NS/RKM/0201/03 dated 2 February 2001.

-យោងឯកសារអាជ្ញាប័ណ្ណលេខ០៩០ ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញឲ្យក្រុមហ៊ុន វាសនា ញូ លែន ផៅវ័រ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤

-Refer to the License Document No.090 LD issued by Electricity Authority of Cambodia to Veasna New Land Power Co., Ltd dated March 16, 2004.

-យោងលិខិតស្នើសុំពង្រីកតំបន់ចែកចាយ និងសុំបង្កើនអាណត្តិរបស់ក្រុមហ៊ុន វាសនា ញូ លែន ផៅវ័រ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៤

-Refer to the requested letter of Veasna New Land Power Co., Ltd for extending distribution area increasing term dated February 03, 2014.

-យោងកំណត់បង្ហាញសុំបង្កើនអាណត្តិរបស់លេខាធិការដ្ឋានលេខ ០៤១-១៤-លជ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៤

- In accordance with the request for increasing term of Secretariat Office No. 041-14 dated May 08, 2014.

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៤

-In accordance with the consultation with concerned parties and public, made from April 02, 2014 to May 15, 2014.

-យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី ២៧១ នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៤

-In accordance with the decision of Electricity Authority of Cambodia's Session No. 271 dated December 09, 2014.

## សម្រេច

## DECIDES

| | |
|---|---|
| **ប្រការ១**<br>កែសម្រួលឯកសារអាជ្ញាប័ណ្ណលេខ ០៩០ ឯអ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ ២០០៤ ដែលបានផ្តល់ជូន**ក្រុមហ៊ុន វាសនា ញូលែន ផៅវើ**(បន្ទាប់ពីនេះហៅថា «**អ្នកកាន់អាជ្ញាប័ណ្ណ**»)សម្រាប់ធ្វើសេវាកម្មអគ្គិសនីក្នុងតំបន់អនុញ្ញាត ដែលកំណត់ក្នុងឧបសម្ព័ន្ធទី១ សម្រាប់ផ្តល់សិទ្ធិឲ្យអ្នកកាន់អាជ្ញាប័ណ្ណដូចខាងក្រោមៈ<br>- ដោយសារអ្នកកាន់អាជ្ញាប័ណ្ណបានសាងសង់ និង កែលម្អមធ្យោបាយធ្វើសេវាកម្មអគ្គិសនីស្របតាមស្តង់ដាបច្ចេកទេសអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចកែសម្រួលឯកសារអាជ្ញាប័ណ្ណលេខ ០៩០ ឯអ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤ ដែលបានផ្តល់ជូនអ្នកកាន់អាជ្ញាប័ណ្ណដោយបង្កើនអាណត្តិអាជ្ញាប័ណ្ណពី ១០(ដប់)ឆ្នាំ ទៅ ១២(ដប់ពីរ) ឆ្នាំ ។ អាណត្តិថ្មីរបស់អាជ្ញាប័ណ្ណនេះមានរយៈពេល ១២ (ដប់ពីរ)ឆ្នាំ គិតចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៩ និងអាចស្នើសុំបន្តទៀត ឬស្នើសុំកែសម្រួលបាន លើកលែងតែត្រូវដកហូតដោយអនុលោមតាមល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ។<br>- អនុញ្ញាតឲ្យអ្នកកាន់អាជ្ញាប័ណ្ណពង្រីកតំបន់ចែកចាយអគ្គិសនីបន្ថែមលើតំបន់ចែកចាយអគ្គិសនីដែលមានស្រាប់ មានបង្ហាញក្នុងផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ កែសម្រួលថ្មី ។ | **Article 1**<br>To revise the license document No. 090 LD dated March 16, 2004 issued to **Veasna New Land Power Co., Ltd** (herein after referred to as "Licensee") in order to supply the electric power services in authorized distribution area is determined in schedule 1, by giving the rights to licensee as follows:<br>- As the licensee has improved its of facilities accordance with Electric Power Technical Standards of the Kingdom of Cambodia, EAC decides to revise license document No. 090 LD dated March 16, 2004 granted to licensee by increasing term of license from 10 (Ten) years to 12 (Twelve) years. The new term of the license shall be 12 (Twelve) years from March 16, 2009 and may be renewed for further periods unless revoked earlier in accordance with the conditions of license.<br>- To provide the right to licensee to add more distribution area to its existing areas as shown in the attached map in new revised schedule1. |
| **ប្រការ២**<br>ប្រការ១(ក) ក្នុងផ្នែកទី១ និងឧបសម្ព័ន្ធទី២ នៃឯកសារអាជ្ញាប័ណ្ណលេខ ០៩០ ឯអ ត្រូវបានលុបចេញពីឯកសារអាជ្ញាប័ណ្ណលេខ ០៩០ ឯអ ។ | **Article 2**<br>Article 1 (a) of Part I and Schedule 2 of the license documents No. 090 LD is deleted. |
| **ប្រការ៣**<br>ឧបសម្ព័ន្ធទី១ចាស់ នៃឯកសារអាជ្ញាប័ណ្ណលេខ ០៩០ ឯអ ត្រូវជំនួសដោយឧបសម្ព័ន្ធទី១ កែសម្រួលថ្មី ដែលមានភ្ជាប់មកជាមួយ ។ | **Article 3**<br>The existing schedule 1 of the license document No. 090 LD is replaced by the new revised schedule 1 attached herewith. |
| **ប្រការ៤**<br>ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណ លេខ ០៩០ ឯអ ត្រូវស្ថិតនៅជាធរមានដដែល ។ | **Article 4**<br>The other contents and conditions of the license document No. 090 LD shall remain unaltered and in force. |
| **ប្រការ៥**<br>សេចក្តីសម្រេចនេះ ត្រូវចាត់ទុកជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ០៩០ ឯអ ។ | **Article 5**<br>This decision shall be considered as a part of the license document No. 090 LD. |
| **ប្រការ៦**<br>សេចក្តីសម្រេចនេះត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ | **Article 6**<br>This decision shall come into force from the date of signing. |

| | |
|---|---|
| **ប្រការ៧**<br>អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើសេចក្តីសម្រេចនេះ ទៅតម្កល់ទុកបន្ថែមនៅតាមទីកន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ ០៩០ ឯអ បានតម្កល់ទុកពីមុនដើម្បីឲ្យឯកសារអាជ្ញាប័ណ្ណលេខ ០៩០ ឯអ ដែលតម្កល់ទុកមានការកែសម្រួល ជាថ្មីស្រប តាមសេចក្តីសម្រេចនេះ ។ | **Article 7**<br>The licensee shall send this decision to deposit additionally at the places, where the license document No. 090 LD has been deposited in order that the deposited license document No. 090 LD is in conformity with this decision. |

ភ្នំពេញ, ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៤

Phnom Penh, December 09, 2014

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

CHAIRMAN OF ELECTRICITY AUTHORITY OF CAMBODIA

**បណ្ឌិត.ទី នរិន្ទ**

# ឧបសម្ព័ន្ធទី១
# តំបន់អនុញ្ញាតឲ្យចែកចាយអគ្គិសនី
# ធ្វើការកែសម្រួលជាថ្មី ក្នុងសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
# លើកទី ២៧១ នាថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៤

# SCHEDULE 1

## AUTHORIZED DISTRIBUTION AREAS

## AS AMENDED IN SESSION OF EAC No. 271 DATED DECEMBER 09, 2014

| | |
|---|---|
| ១- តំបន់អនុញ្ញាតឲ្យចែកចាយអគ្គិសនី ដែលអ្នកកាន់អាជ្ញាប័ណ្ណមានសិទ្ធិផ្តល់សេវាចែកចាយ និងផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់គឺនៅផ្នែកខ្លះនៃខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ស្រុកមុខកំពូល ស្រុកពញាឮ ខេត្តកណ្តាល និងស្រុកបាធាយ ខេត្តកំពង់ចាម ។ | 1. The authorizes distribution Areas, where the licensee have the right to provide the electricity distribution and supply services are some part of Khan Russey Keo, Phnom Penh, Mokkampoul, Ponhealeu Districts, Kandal Province and Batheay District, Kampong Cham Province. |
| ២- តំបន់អនុញ្ញាតឲ្យចែកចាយអគ្គិសនីនេះ កំណត់ដោយ " ផែនទីកំណត់ព្រំប្រទល់លេខ 090LD-Veasna New Land Power–LR7–MR5-2014" ដែលភ្ជាប់មកជាមួយ ។ | 2. The authorizes distribution area is determined by "the boundary map No. 090LD-Veasna New Land Power–LR7–MR5-2014" attached. |
| ៣- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណមានបំណងស្នើសុំពង្រីកតំបន់ចែកចាយថែមទៀត ពេលនោះអ្នកកាន់អាជ្ញាប័ណ្ណត្រូវរៀបចំកំណត់ឯកសារចាំបាច់នានា ដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជាតាមការរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជា ចេញសេចក្តីសម្រេចអនុញ្ញាតឲ្យពង្រីកតំបន់ចែកចាយណាមួយ ឧបសម្ព័ន្ធទី១នេះ ត្រូវធ្វើការកែសម្រួលដោយភ្ជាប់ជាមួយសេចក្តីសម្រេចឲ្យពង្រីកតំបន់ចែកចាយនោះ ។ | 3. Under this license, if the licensee intends to request the extension distribution areas then he shall prepare all necessary documents and submit to EAC in accordance with the EAC's determination. After EAC authorized to extend distribution area, this schedule 1 shall be revised and attached with that authorization. |

E A C

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរអគ្គិសនីកម្ពុជា
ELECTRICITY AUTHORITY OF CAMBODIA
លេខ ៖០១/៤៤សរ១២-អអក

# សេចក្តីសម្រេចកែសម្រួលលើកទី៦ លើឯកសារអាជ្ញាប័ណ្ណ លេខ ០៩០ ឯអ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤ របស់ក្រុមហ៊ុន វាសនា ញូលែន ផៅវ័រ

# DECISION ON THE SIXTH REVISION OF THE LICENSE DOCUMENT No. 090 LD DATED MARCH 16, 2004 FOR VEASNA NEW LAND POWER CO., Ltd

## អាជ្ញាធរអគ្គិសនីកម្ពុជា
## ELECTRICITY AUTHORITY OF CAMBODIA

- អនុវត្តតាមមាត្រា ៧, ២៩ និង ៣៤ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស.រកម.០២០១.០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

-In exercise of the powers conferred by Article 7, 29 and 34 of the Electricity Law promulgated by the Royal Decree No. NS/RKM/0201/03 dated 2 February 2001.

-យោងឯកសារអាជ្ញាប័ណ្ណរបស់ក្រុមហ៊ុន វាសនា ញូលែន ផៅវ៉ែ លេខ ០៩០ ឯអ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤

-Refer to the License Document of Veasna New Land Power Co., Ltd No.090 LD dated March 16, 2004.

-យោងប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល លេខ ៦២៤ឧរថ.អគថ.ប្រក ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១១

-In accordance with the Prakas of Ministry of Industry, Mines and Energy No. 624 daded July 08, 2011

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១១ ដល់ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១១

-In accordance with the consultation with concerned parties and public, made from September 20, 2011 to October 30, 2011

-យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី២៣០ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១២

-In accordance with the decision of Electricity Authority of Cambodia's Session No.230 dated, June 29, 2012.

## សម្រេច

## DECIDES

| | |
|---|---|
| **ប្រការ ១**<br>កែសម្រួលឯកសារអាជ្ញាប័ណ្ណលេខ ០៩០ ឯអ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤ ដែលបានផ្តល់ជូនក្រុមហ៊ុន វាសនា ញូលែន ផៅវ័រ (បន្ទាប់ពីនេះហៅថា "**អ្នកកាន់អាជ្ញាប័ណ្ណ**") សម្រាប់ធ្វើសេវាកម្មអគ្គិសនីក្នុងតំបន់អនុញ្ញាតដែលកំណត់ក្នុងឧបសម្ព័ន្ធទី១ ដើម្បីដកតំបន់ចែកចាយមួយផ្នែកនៃសង្កាត់ព្រែកតាសេក និងសង្កាត់បាក់ខែង ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ និងឃុំសំបួរមាស ស្រុកមុខកំពូល ខេត្តកណ្តាល ចេញពីតំបន់ចែកចាយដែលមានស្រាប់ (ដូចមានបង្ហាញក្នុងផែនទី ភ្ជាប់ក្នុងឧបសម្ព័ន្ធ១ កែសម្រួលថ្មី) ។ | **Article 1**<br>To revise the license document No. 090 LD dated March 16, 2004 granted to **Veasna New Land Power Co., Ltd** (herein after referred to as "**Licensee**"), to provide the electric power service in authorized distribution area is determind in schedule 1, to withdrawal a part of Sangkat Prek Tasek and Sangkat Bakheng, Khan Russey Keo, Phnom Penh and Khan Sambuor Meas, Mokampoul District, Kandal Province from the existing distribution area (As shown in the attached map in new revised schedule 1). |
| **ប្រការ ២**<br>ឧបសម្ព័ន្ធទី១ ចាស់នៃឯកសារអាជ្ញាប័ណ្ណលេខ ០៩០ ឯអ ត្រូវជំនួសដោយឧបសម្ព័ន្ធទី១ កែសម្រួលថ្មីដែលមានភ្ជាប់មកជាមួយ ។ | **Article 2**<br>The existing schedule 1 of the license document No. 090 LD is replaced by the new revised schedule 1 attached here with. |
| **ប្រការ ៣**<br>ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណ លេខ ០៩០ ឯអ ត្រូវស្ថិត នៅជាធរមានដដែល ។ | **Article 3**<br>The other contents and conditions of the license document No. 090 LD shall remain unaltered and in force. |
| **ប្រការ ៤**<br>សេចក្តីសម្រេចនេះ ត្រូវចាត់ទុកជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ០៩០ឯអ ។ | **Article 4**<br>This decision shall be considered as a part of the license document No. 090 LD. |
| **ប្រការ ៥**<br>សេចក្តីសម្រេចនេះត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ | **Article 5**<br>The decision shall come into force from the date of signing. |
| **ប្រការ ៦**<br>អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើសេចក្តីសម្រេចនេះទៅតម្កល់ទុកបន្ថែមនៅតាមទីកន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ ០៩០ ឯអ បានតម្កល់ទុកពីមុន ដើម្បីឲ្យឯកសារអាជ្ញាប័ណ្ណលេខ ០៩០ ឯអ ដែលតម្កល់ទុក មានការកែសម្រួលជាថ្មីស្របតាមសេចក្តីសម្រេចនេះ ។ | **Article 6**<br>The licensee shall send this decision to deposit additionally at the places, where the license document No. 090 LD has been deposited in order that the deposited license document No. 090 LD is in conformity with this decision. |

ភ្នំពេញ, ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១២

Phnom Penh, June 29, 2012

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

CHAIRMAN OF ELECTRICITY AUTHORITY OF CAMBODIA

**បណ្ឌិត.ទី នរិន្ទ**

# អាជ្ញាធរអគ្គិសនីកម្ពុជា
ELECTRICITY AUTHORITY OF CAMBODIA

## ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
ELECTRICITY LAW OF THE KINGDOM OF CAMBODIA

# អាជ្ញាប័ណ្ណរួមសំរាប់ធ្វើសេវាកម្មផលិត និងចែកចាយ អគ្គិសនីនៅភូមិបាក់ខែង និងភូមិខ្ទរ សង្កាត់ព្រែកលៀប ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ

**CONSOLIDATED LICENSE FOR PROVIDING ELECTRIC POWER GENERATION AND DISTRIBUTION SERVICES AT PHUM BAK KHENG AND PHUM KTOR, SANGKAT PREK LEAP, KHAN RUSEY KEO, PHNOM PENH**

## លោក វ៉េន វាសនា
**MR. VEN VEASNA**

**ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤**
16 March 2004

# ផ្នែកទី១
# សេចក្តីសំរេចផ្តល់សិទ្ធិឱ្យធ្វើសេវាកម្ម

# PART 1
# DECISION TO GRANT THE RIGHT TO PROVIDE THE ELECTRIC POWER SERVICE

**ព្រះរាជាណាចក្រកម្ពុជា**

**KINGDOM OF CAMBODIA**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**NATION RELIGION KING**

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ELECTRICITY AUTHORITY OF CAMBODIA**

**លេខ : -០៤ អអក**

# ឯកសារអាជ្ញាប័ណ្ណលេខ ០៩០ ឯអ

# LICENSE DOCUMENT No. 090 LD

# អាជ្ញាប័ណ្ណរួមសំរាប់ លោក វ៉ែន វាសនា

# CONSOLIDATED LICENSE FOR MR. VEN VEASNA

# អាជ្ញាធរអគ្គិសនីកម្ពុជា

# ELECTRICITY AUTHORITY OF CAMBODIA

-អនុវត្តតាមមាត្រា ៧ និង ២៩ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ ។

- In exercise of the powers conferred by Article 7 and 29 of the Electricity Law promulgated by the Royal Decree NS/RKM/0201/03, dated 02/02/2001.

-យោងលិខិតអនុញ្ញាតរបស់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលរាជធានីភ្នំពេញ លេខ ០០៩សស.ថត ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០២។

- In accordance with Authorized Letter of Phnom Penh Municipality Department of Industry, Mines and Energy N° 009 dated November 28, 2002.

-យោងតាមពាក្យស្នើសុំអាជ្ញាប័ណ្ណរួមរបស់ លោក វ៉ែន វាសនា ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០២ ។

- In accordance with the application for license of Mr. VEN VEASNA dated November 22, 2002.

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកកាន់អាជ្ញាប័ណ្ណ ស្ថាប័នពាក់ព័ន្ធ និងសាធារណជន ចាប់ពីថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៣ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៣ ។

-In accordance with the consultation with licensee, concerned parties and public, made from October 29, 2003 to November 30, 2003.

-យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី៣៥ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤

- In accordance with the decision of Electricity Authority of Cambodia's Session No.35 Dated March 16, 2004

## សំរេច

## DECIDES

| | |
|---|---|
| **ប្រការ១** | **Article 1** |
| ផ្តល់**អាជ្ញាប័ណ្ណរួម** ជូន **លោក វ៉ែន វាសនា** (បន្ទាប់ពីនេះហៅថា "**អ្នកកាន់អាជ្ញាប័ណ្ណ** ") ភេទប្រុស ជនជាតិខ្មែរ ឆ្នាំកំណើត ១៩៥៧ ទីលំនៅបច្ចុប្បន្ន ភូមិទី ១០ សង្កាត់ជ្រោយចង្វារ ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាន់អត្តសញ្ញាណប័ណ្ណលេខ ៣៤៤១២៤ ភព ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩២ ដែលជាសេវាករកំពុងធ្វើសេវាកម្មអគ្គិសនីនៅភូមិបាក់ខែង និងភូមិខ្ទរ សង្កាត់ព្រែកលៀប ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ សំរាប់ផ្តល់សិទ្ធិឱ្យអ្នកកាន់អាជ្ញាប័ណ្ណដូចខាងក្រោម : | There is hereby granted the **Consolidated License** to **Mr. VEN VEASNA** (herein after referred to as **"Licensee")** Sex male Nationality Khmer, Date of Birth 1957, Permanent Address Phum No.10, Sangkat Chroychangva, Khan Rusey Keo, Phnom Penh, holding Identification Card No. 344124 dated October 13, 1992, which electric power service provider at Phum Bak Kheng and Phum Ktor, Sangkat Prek Lep, Khan Rusey Keo, Phnom Penh for giving the right to the licensee as follow: |
| (ក) បន្តធ្វើសេវាកម្មផលិតកម្មអគ្គិសនីនៅភូមិបាក់ខែង សង្កាត់ព្រែកលៀប ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដើម្បីផ្គត់ផ្គង់អគ្គិសនីឱ្យប្រព័ន្ធចែកចាយរបស់ខ្លួនតាមមធ្យោបាយផលិតកម្មដែលកំណត់ក្នុង ឧបសម្ព័ន្ធទី២ ក្នុងរយៈពេលដែលកំណត់ដោយ ប្រការ៣ ផ្នែកទី១ខាងក្រោម ដោយត្រូវគោរពតាមល័ក្ខខ័ណ្ឌនានាដែលមានចែងក្នុងផ្នែកទី២នៃអាជ្ញាប័ណ្ណនេះ ។ សិទ្ធិនេះអាចត្រូវជំនួសដោយការទិញអគ្គិសនីដុំពីអគ្គិសនីកម្ពុជាយកមកចែកចាយ ។ ក្នុងករណីអ្នកកាន់អាជ្ញាប័ណ្ណមានបំណងទិញអគ្គិសនីដុំពីអគ្គិសនីកម្ពុជា អ្នកកាន់អាជ្ញាប័ណ្ណត្រូវធ្វើការចរចារជាមួយអគ្គិសនីកម្ពុជា និងត្រូវស្នើសុំការយល់ព្រមពីអាជ្ញាធរអគ្គិសនីកម្ពុជាមុនពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀងទិញ–លក់ជាមួយអគ្គិសនីកម្ពុជា ។ អាជ្ញាធរអគ្គិសនីកម្ពុជាអាចធ្វើការកែសំរួលខ្លឹមសារអាជ្ញាប័ណ្ណនេះឡើងវិញដើម្បីឱ្យសមស្របតាមរូបភាពអាជីវកម្ម ។ | (a) to continue to generate electricity at Phum Bak Kheng, Sangkat Prek Lep, Khan Rusey Keo, Phnom Penh for the purpose of supply electric power to his distribution systems by generating facilities defined in schedule 2, during the period specified in Article 3 of Part 1, subject to the conditions set out in Part 2 of this License. This right can be replaced by bulk purchasing from Electricite du Cambodge for distribution. In case the licensee intents to purchase power from Electricite du Cambodge in bulk scale, the licensee shall negotiate with Electricite du Cambodge and submit to EAC for approval before signing the power purchase agreement. EAC can revise content of the license for adapting the business scheme. |
| (ខ) បន្តធ្វើសេវាកម្មចែកចាយ និងលក់អគ្គិសនីឱ្យអ្នកប្រើប្រាស់ក្នុងតំបន់ចែកចាយដែលកំណត់ក្នុង ឧបសម្ព័ន្ធទី១ ផ្នែកទី២របស់អាជ្ញាប័ណ្ណនេះ ក្នុងរយៈពេលដែលកំណត់ដោយ ប្រការ៣ ផ្នែកទី១ខាងក្រោម ដោយត្រូវគោរពតាមល័ក្ខខ័ណ្ឌនានា ដែលមានចែងក្នុងផ្នែកទី២នៃអាជ្ញាប័ណ្ណនេះ ។ | (b) to continue distribute and supply electricity to consumers in the Authorized Distribution Areas defined in Schedule 1, Part 2 of this License, during the period specified in Article 3 of Part 1, subject to the Conditions set out in Part 2 of this License. |
| **ប្រការ២** | **Article 2** |
| ល័ក្ខខ័ណ្ឌនានារបស់អាជ្ញាប័ណ្ណនេះអាចកែសំរួល ឬ ធ្វើវិសោធនកម្មបានអនុលោមតាមបញ្ញត្តិរបស់អាជ្ញាប័ណ្ណនេះ ឬ តាមមាត្រា៧ និង ៤៤ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។ អាជ្ញាប័ណ្ណដែលផ្តល់ឱ្យនេះអាចដកហូតបានស្របតាមល័ក្ខខ័ណ្ឌដែលកំណត់ក្នុង ឧបសម្ព័ន្ធទី៣ផ្នែកទី២របស់អាជ្ញាប័ណ្ណ ។ | The Conditions referred to above license are subject to modification or amendment in accordance with their terms or with Article 7 and 44 of the Electricity Law of the Kingdom of Cambodia. This license hereby granted is further subject to the terms as to revocation specified in Schedule 3 of Part 2 of this License. |
| **ប្រការ៣** | **Article 3** |
| អាជ្ញាប័ណ្ណនេះ ត្រូវចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ និងមានអាណត្តិចំនួន ០៥ ឆ្នាំ និងអាចសុំបន្តទៀតបានលើកលែងតែត្រូវបានដកហូតដោយអនុលោមតាមល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ឬត្រូវបានកែសំរួលឡើងវិញ ក្នុងករណីមានការតម្រូវពីអាជ្ញាធរអគ្គិសនីកម្ពុជា ឱ្យអ្នកកាន់អាជ្ញាប័ណ្ណទិញភ្លើងពីអគ្គិសនីកម្ពុជា ។ | This license shall come into force from the date it is signed, unless revoked earlier in accordance with the conditions of license, the term of license shall be 05 years and may be renewed for further periods or revised the contents in case of requiring from EAC to purchase the electric power from EDC. |

ភ្នំពេញ, ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤

Phnom Penh, March 16, 2004

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

CHAIRMAN OF ELECTRICITY AUTHORITY OF CAMBODIA

# ផ្នែកទី២
# លក្ខខណ្ឌរបស់អាជ្ញាប័ណ្ណ
# PART 2
# CONDITIONS OF LICENSE

# មាតិកា

TABLE OF CONTENTS


| | |
|---|---|
| **១ និយមន័យរបស់ពាក្យប្រើក្នុងអាជ្ញាប័ណ្ណ** | **1 Definitions of Terms used in the License** |
| **២ កាតព្វកិច្ចទូទៅរបស់អ្នកកាន់អាជ្ញាប័ណ្ណ** | **2 General Obligation of Licensee** |
| ល័ក្ខខ័ណ្ឌទី១ : កាតព្វកិច្ចគោរពច្បាប់ និងអនុក្រឹត្យ | Condition 1: Obligation on compliance with Laws and Sub-decrees |
| ល័ក្ខខ័ណ្ឌទី២ : កាតព្វកិច្ចគោរពតាមស្តង់ដារបច្ចេកទេស សុវត្ថិភាព និង បរិស្ថាន | Condition 2: Obligation on compliance with Technical Standard, Safety and Environment |
| ល័ក្ខខ័ណ្ឌទី៣ : កាតព្វកិច្ចគោរពតាមបទបញ្ជា ឬសេចក្តីសំរេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ក្នុងការដាក់វិធាន បទប្បញ្ញត្តិ និងនីតិវិធីនានាសំរាប់ការធ្វើសេវាកម្មផលិត និងចែកចាយ | Condition 3: Obligation on compliance with Orders or Decision of EAC in issuing Rules, Regulations and Procedures for Generation and Distribution Services |
| ល័ក្ខខ័ណ្ឌទី៤ : កាតព្វកិច្ចគោរពតាមល័ក្ខខ័ណ្ឌសេវាកម្ម ដែលកំណត់ក្នុងអាជ្ញាប័ណ្ណរបស់ខ្លួន | Condition 4: Obligation on compliance with Conditions of Electric Power Service specified in its License |
| ល័ក្ខខ័ណ្ឌទី៥ : កាតព្វកិច្ចធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សកម្មភាពសេវាកម្មរបស់ខ្លួនតាមការកំណត់របស់អាជ្ញាធរអគ្គិសនីកម្ពុជា | Condition 5: Obligation on Financial Statement and its Electric Power Service Report in accordance with EAC's Adoption |
| ល័ក្ខខ័ណ្ឌទី៦ : កាតព្វកិច្ចបង់កម្រៃអាជ្ញាប័ណ្ណ | Condition 6: Obligation on Payment of License Fee |
| **៣ ល័ក្ខខ័ណ្ឌសេវាកម្ម** | **3 Service Conditions** |
| **៣.១ ល័ក្ខខ័ណ្ឌទូទៅ** | **3.1 General Conditions** |
| ល័ក្ខខ័ណ្ឌទី៧ : ការទំនាក់ទំនង | Condition 7: Communication |
| ល័ក្ខខ័ណ្ឌទី៨ : ល័ក្ខខ័ណ្ឌពាក់ព័ន្ធនិងផលប្រយោជន៍សាធារណៈ | Condition 8: Conditions on the Public Interest |
| ល័ក្ខខ័ណ្ឌទី៩ : ល័ក្ខខ័ណ្ឌចំពោះការធ្វើអាជីវកម្ម | Condition 9: Conditions on the Business |
| ល័ក្ខខ័ណ្ឌទី១០ : ល័ក្ខខ័ណ្ឌលក់មធ្យោបាយធ្វើសេវាកម្ម ក្នុងករណីមានការតម្រូវពីអាជ្ញាធរអគ្គិសនីកម្ពុជា | Condition 10: Sale Condition of Service Facilities in the case it is required from EAC |
| **៣.២ ល័ក្ខខ័ណ្ឌសេវាកម្មផលិតកម្ម** | **3.2 Conditions on Generation Service** |
| ល័ក្ខខ័ណ្ឌទី១១ : ល័ក្ខខ័ណ្ឌចំពោះមធ្យោបាយផលិតកម្ម | Condition 11: Conditions on the Generation Facilities |
| ល័ក្ខខ័ណ្ឌទី១២ : ល័ក្ខខ័ណ្ឌចំពោះកិច្ចដំណើរការផលិតកម្ម | Condition 12: Conditions on the Generation Operation |
| **៣.៣ ល័ក្ខខ័ណ្ឌសេវាកម្មចែកចាយ** | **3.3 Conditions on Distribution Service** |
| ល័ក្ខខ័ណ្ឌទី១៣ : ល័ក្ខខ័ណ្ឌចំពោះតំបន់ធ្វើសេវាកម្ម | Condition 13: Condition on Electric Power Service Area |
| ល័ក្ខខ័ណ្ឌទី១៤ : ល័ក្ខខ័ណ្ឌចំពោះមធ្យោបាយធ្វើសេវាកម្ម | Condition 14: Condition on Electric Power Service Utilities |
| ល័ក្ខខ័ណ្ឌទី១៥ : ល័ក្ខខ័ណ្ឌចំពោះកិច្ចដំណើរការប្រព័ន្ធចែកចាយ | Condition 15: Condition on Distribution System Operation |
| ល័ក្ខខ័ណ្ឌទី១៦ : ល័ក្ខខ័ណ្ឌចំពោះការផ្គត់ផ្គង់អគ្គិសនីឱ្យអតិថិជន | Condition 16: Condition on Electric Power Supply to Customers |
| **ឧបសម្ព័ន្ធទី១** : តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី | **SCHEDULE 1:** Authorized Distributing Area |
| **ឧបសម្ព័ន្ធទី២** : មធ្យោបាយផលិតកម្មដែលមានស្រាប់របស់អ្នកកាន់អាជ្ញាប័ណ្ណ | **SCHEDULE 2:** Existing Generating Facilities of the Licensee |
| **ឧបសម្ព័ន្ធទី៣** : ល័ក្ខខ័ណ្ឌសំរាប់ធ្វើការដកហូតអាជ្ញាប័ណ្ណ | **SCHEDULE 3:** Term of Revocation |

# លក្ខខណ្ឌរបស់អាជ្ញាប័ណ្ណ
# CONDITIONS OF LICENSE

## ១ និយមន័យរបស់ពាក្យប្រើក្នុងអាជ្ញាប័ណ្ណ
## 1 DEFINITIONS OF TERMS USED IN THE LICENSE

| | | | |
|---|---|---|---|
| ពាក្យពេចន៍ទាំងឡាយណាដែលបានប្រើប្រាស់ក្នុងឯកសារអាជ្ញាប័ណ្ណនេះ ឬផ្នែកណាមួយរបស់ឯកសារនេះ និងនៅក្នុងឧបសម្ព័ន្ធភ្ជាប់ ប្រសិនបើពុំមានការបញ្ជាក់ខ្លឹមសារផ្សេងទេ ត្រូវមានន័យដូចខាងក្រោម : | | In this or any of the following Parts of this document and in the Schedules below, unless otherwise specified or the context otherwise requires: | |
| "សវនកម្ម " | មានន័យថា ការជំរះបញ្ជីលើរបាការណ៍ហិរញ្ញវត្ថុរបស់អ្នកកាន់អាជ្ញាប័ណ្ណ ក្នុងឆ្នាំការិយបរិច្ឆេទដោយសវនករមួយ ។ | "Audit" | means audit on the Licensee's Financial Statement of a financial year by an auditor. |
| "លក្ខខ័ណ្ឌ " | មានន័យថា លក្ខខ័ណ្ឌដែលចែងក្នុងអាជ្ញាប័ណ្ណនេះ ។ | "Condition" | means a Condition set out in this License. |
| "អ្នកប្រើប្រាស់ធុនតូច" | គឺអ្នកប្រើប្រាស់ទាំងឡាយណា ដែលទទួលការផ្គត់ផ្គង់អគ្គិសនីតាមតង់ស្យុងទាប (២២០វ៉ុល) ១ហ្វា ។ | "Small Consumers" | are consumers supplied power at single phase and low voltage (220 Volts). |
| "អ្នកប្រើប្រាស់ធុនមធ្យម" | គឺអ្នកប្រើប្រាស់ទាំងឡាយណាដែលទទួលការផ្គត់ផ្គង់អគ្គិសនីតាមតង់ស្យុងទាប (៣៨០វ៉ុល) ៣ ហ្វា។ | "Medium Consumers" | are consumers supplied power at three phases and low voltage (380 Volts). |
| "អ្នកប្រើប្រាស់ធុនធំ" | គឺអ្នកប្រើប្រាស់ទាំងឡាយណា ដែលទទួលការផ្គត់ផ្គង់អគ្គិសនីតាមតង់ស្យុងមធ្យម (លើសពី ៣៨០វ៉ុល និងរហូតដល់ ២២ ០០០ វ៉ុល) ។ | "Big Consumers" | are consumers supplied power at medium voltage (above 380 Volts to 22 000 Volts). |
| "អ្នកប្រើប្រាស់ដុំ" | គឺអ្នកប្រើប្រាស់ទាំងឡាយណា ដែលទទួលការផ្គត់ផ្គង់អគ្គិសនីតាមតង់ស្យុងខ្ពស់ (លើសពី ២២ ០០០វ៉ុល) ។ | "Bulk Consumers" | are consumers supplied power at high voltage (above 22 000 Volts). |
| "អតិថិជន " | មានន័យថា បុគ្គលណាមួយដែលបានទទួលការផ្គត់ផ្គង់ ឬទាមទារឱ្យមានការផ្គត់ផ្គង់អគ្គិសនីឱ្យទីតាំងខ្លួនក្នុងតំបន់អនុញ្ញាត ។ | "Customer" | means any person supplied or requiring to be supplied with electricity at premises within the authorized area. |
| "អាជីវកម្មចែកចាយ " | មានន័យថា ការធ្វើអាជីវកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណចែកចាយ ឬមានលក្ខណៈជា :<br>(ក) ការចែកចាយអគ្គិសនី តាមរយៈប្រព័ន្ធចែកចាយរបស់អ្នកកាន់អាជ្ញាប័ណ្ណ គិតរួមទាំងអាជីវកម្មក្នុងការផ្គត់ផ្គង់ ការតភ្ជាប់ប្រព័ន្ធជាមួយប្រព័ន្ធនេះ,<br>(ខ) ការផ្តល់សេវាសំរាប់នាឡិកាស្ទង់ និង<br>(គ) ការផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់ ។ | "Distribution Business" | means the business of the Distribution Licensee or ancillary to:<br>(a) the distribution of electricity through the Licensee's Distribution System, including any business in providing connections to such system;<br>(b) provision of Metering Services; and<br>(c) ©supply of electricity to consumers. |
| "អាជ្ញាប័ណ្ណចែកចាយ " | មានន័យថា អាជ្ញាប័ណ្ណចែកចាយដែលបានផ្តល់ក្នុងប្រការ១(ខ) នៃផ្នែកទី១ ។ | "Distribution License" | means the Distribution License granted in Article 1(b) of Part 1. |
| "ប្រព័ន្ធចែកចាយ " | មានន័យថា ខ្សែបណ្តាញអគ្គិសនីទាំងអស់របស់អ្នកកាន់អាជ្ញាប័ណ្ណក្នុងតំបន់ចែកចាយ ដែលបានអនុញ្ញាត និងខ្សែបណ្តាញអគ្គិសនីណាមួយផ្សេងទៀត ដែលអាជ្ញាធរអគ្គិសនីកម្ពុជាអាចបញ្ជាក់ថា ជាផ្នែកនៃប្រព័ន្ធចែកចាយរបស់អ្នកកាន់អាជ្ញាប័ណ្ណ ព្រមទាំងនាឡិកាស្ទង់ | "Distribution System" | Means all electric network of the Licensee within the Licensee's authorized distribution area and any other electric lines which EAC may specify as forming part of the Licensee's Distribution System, and includes any |

| | | | |
|---|---|---|---|
| | និង បរិក្ខារអគ្គិសនីណាមួយរបស់អ្នកកាន់អាជ្ញាប័ណ្ណ ដែលបានប្រើប្រាស់ សំរាប់ចែកចាយអគ្គិសនីដោយ អ្នកកាន់អាជ្ញាប័ណ្ណ ដោយឡែកចំពោះអ្នកចែកចាយ ដទៃណាមួយផ្សេងទៀត វាមានអត្ថន័យដូចគ្នា ដូច មានចែងក្នុងអាជ្ញាប័ណ្ណ ដែលបានកាន់ដោយអ្នកកាន់ អាជ្ញាប័ណ្ណចែកចាយនោះ ។ | | electrical plant and meters of the Licensee which are used in connection with the distribution of electricity by the Licensee; and, in relation to any other distributor, it shall have the same meaning as it has in the license held by such distributor. |
| "អ្នកចែកចាយ" | មានន័យថា បុគ្គលណាមួយដែលបានកាន់អាជ្ញាប័ណ្ណ ចែកចាយ ។ | "Distributor" | means any person who holds a Distribution License. |
| "អាជ្ញាធរអគ្គិសនីកម្ពុជា" | មានន័យថា អាជ្ញាធរអគ្គិសនីកម្ពុជា ដែលបានបង្កើតឡើងដោយច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០០១ | "EAC" | means the Electricity Authority of Cambodia established by the Electricity Law promulgated by Royal Decree No. NS/RKM/ 0201/03 dated February 2, 2001. |
| "អាជីវកម្មផលិតកម្ម" | មានន័យថា ការធ្វើអាជីវកម្ម (ប្រសិនបើមាន) របស់អ្នកកាន់អាជ្ញាប័ណ្ណ (អ្នកកាន់អាជ្ញាប័ណ្ណផលិត) ក្នុងការផលិតថាមពលអគ្គិសនី ។ | "Generation Business" | means the business (if any) of the Licensee (as holder of the Generation License) in the generation of electricity. |
| "អាជ្ញាប័ណ្ណផលិតកម្ម" | មានន័យថា អាជ្ញាប័ណ្ណ ដែលបានផ្តល់ឱ្យក្នុងប្រការ ១(ក) នៃផ្នែកទី១ ។ | "Generation License" | means the Generation License granted in Article 1 (a) of Part 1. |
| "ឯកសារអាជ្ញាប័ណ្ណ" | មានន័យថា ឯកសារនេះដែលមានពីផ្នែកទី១ ដល់ផ្នែកទី២ និងឧបសម្ព័ន្ធទី១ ដល់ ឧបសម្ព័ន្ធទី៣ ។ | "License Document" | means this document comprising Part 1, Part 2 and Schedules 1 to 3. |
| "អ្នកកាន់អាជ្ញាប័ណ្ណ" | មានន័យថា **លោក វ៉ែន វាសនា** ។ | "Licensee" | means Mr. VEN VEASNA. |
| "បរិក្ខានាឡិកាស្ទង់" | រួមមាន នាឡិកាស្ទង់ និងបរិក្ខាពាក់ព័ន្ធដទៃទៀត ដែលមានឥទ្ធិពលផ្ទាល់ លើការដំណើរការនាឡិកាស្ទង់នោះ ។ | "Metering Equipment" | includes any meter and associated equipment, which materially affects the operation of that meter. |
| "ការជូនដំណឹង" | មានន័យថា (ប្រសិនបើពុំមានការបញ្ជាក់ផ្សេងទៀត) គឺការជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬ ដោយមធ្យោបាយសមស្របណាមួយផ្សេងទៀត ។ | "Notice" | means (unless otherwise specified) notice given in writing or by any other reasonable means. |
| "ការបញ្ជាក់" | រួមមាន ការបដិសេធ ឬ ការសំណូមពរណាមួយ ដែលបានធ្វើជាលាយលក្ខណ៍អក្សរ ។ | "Representation" | includes any objection or any other proposal made in writing. |

## ២ ភារកិច្ចទូទៅរបស់អ្នកកាន់អាជ្ញាប័ណ្ណ

**លក្ខខណ្ឌទី១ : ភារកិច្ចគោរពច្បាប់ និង អនុក្រឹត្យ**

១- អ្នកកាន់អាជ្ញាប័ណ្ណត្រូវគោរពតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

២- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវគោរពតាមកាតព្វកិច្ចបរិស្ថានដែលបានកំណត់ក្នុងច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង អនុក្រឹត្យនានាពាក់ព័ន្ធនឹងការការពារបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា ។

## 2 GENERAL OBLIGATION OF LICENSEE

**Condition 1: Obligation on compliance with Laws and Sub-decrees.**

1. The Licensee shall comply with the Electricity Law of the Kingdom of Cambodia, other Laws and Sub Decrees relating to the Laws.

2. The Licensee is subjected to the environmental obligations as specified in the Law on Environmental Protection promulgated by the Royal Decree NS/RKM/1296/36, dated 24/12/1996 and Other Sub-Decrees on Environmental Protection of the Kingdom of Cambodia

| | |
|---|---|
| **លក្ខខណ្ឌទី២ : ភាតព្វកិច្ចគោរពតាមស្តង់ដារបច្ចេកទេស សុវត្ថិភាព និង បរិស្ថាន** | **Condition 2: Obligation on compliance with Technical Standard, Safety and Environment** |
| ១- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវគោរពតាមស្តង់ដាទាក់ទងទៅនឹងកិច្ចប្រតិបត្តិការបច្ចេកទេស សុវត្ថិភាព និងបរិស្ថាន ដែលបង្កើតឡើង និងផ្សព្វផ្សាយដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ | 1. The Licensee shall comply with the standard relating to technical operation, safety and environment, used and published by Ministry of Industry, Mines and Energy. |
| **លក្ខខណ្ឌទី៣ : ភាតព្វកិច្ចគោរពតាមបទបញ្ជា ឬ សេចក្តីសំរេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការដាក់វិធាន បទប្បញ្ញត្តិ និងនីតិវិធីនានាសំរាប់ការធ្វើសេវាកម្មផលិត និងចែកចាយ** | **Condition 3: Obligation on compliance with Orders or Decisions of EAC in issuing Rules, Regulations and Procedures for Generation and Distribution Services** |
| ១- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវគោរពតាមវិធាន បទប្បញ្ញត្តិ និងនីតិវិធីនានា ដែលអាជ្ញាធរអគ្គិសនីកម្ពុជាសំរេចដាក់ឱ្យអនុវត្ត សំរាប់ការធ្វើសេវាកម្មផលិត និងចែកចាយអគ្គិសនី ។ | 1. The Licensee shall comply with the provisions of the Rules, Regulations and Procedures on the electric power generation and distribution services issued by EAC. |
| ២- ក្នុងករណីជាក់លាក់ណាមួយ អាជ្ញាធរអគ្គិសនីកម្ពុជា (បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអ្នកកាន់អាជ្ញាប័ណ្ណ) អាចចេញលិខិតណែនាំបន្ធូរបន្ថយកាតព្វកិច្ចរបស់អ្នកកាន់អាជ្ញាប័ណ្ណ តាមវាក្យខ័ណ្ឌទី១ចំពោះផ្នែកណាមួយនៃវិធាន បទប្បញ្ញត្តិ នីតិវិធី និង តាមទំហំណាមួយដែលកំណត់ក្នុងលិខិតណែនាំ ។ | 2. In specific case, EAC may (following consultation with the Licensee) issue directions relieving the Licensee of its obligations under paragraph 1 in respect of such parts of the Rules, Regulations or Procedures and for such periods specified in those directions. |
| **លក្ខខណ្ឌទី៤ : ភាតព្វកិច្ចគោរពតាមលក្ខខណ្ឌសេវាកម្ម ដែលកំណត់ក្នុងអាជ្ញាប័ណ្ណរបស់ខ្លួន** | **Condition 4: Obligation on compliance with Conditions of Electric Power Service specified in its License** |
| ១- អ្នកកាន់អាជ្ញាប័ណ្ណត្រូវគោរពតាមល័ក្ខខ័ណ្ឌសេវាកម្ម ដែលកំណត់ក្នុងអាជ្ញាប័ណ្ណនេះ ។ | 1. The Licensee shall comply with the provisions of service condition in this license. |
| **លក្ខខណ្ឌទី៥ : ភាតព្វកិច្ចធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សកម្មភាពសេវាកម្មរបស់ខ្លួន តាមការកំណត់របស់អាជ្ញាធរអគ្គិសនីកម្ពុជា** | **Condition 5: Obligation on Financial Statement and its Electric Power Service Report in accordance with EAC's Adoption** |
| ១- ឆ្នាំការិយបរិច្ឆេទនៃអ្នកកាន់អាជ្ញាប័ណ្ណ ត្រូវចាប់គិតពីថ្ងៃទី ១ ខែមករា រហូតដល់ថ្ងៃទី ៣១ ខែធ្នូ រៀងរាល់ឆ្នាំ ។ | 1. The financial year of the Licensee shall be reckoned every year from 1st January to the following 31st December. |
| ២- អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជា នូវច្បាប់ចំលងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច មិនលើសពី ៣ខែ ក្រោយពីបញ្ចប់ឆ្នាំការិយបរិច្ឆេទដែលរបាយការណ៍នោះពាក់ព័ន្ធ ។ ការធ្វើសវនកម្មអាចជំនួសដោយការត្រួតពិនិត្យរបស់អាជ្ញាធរ ក្នុងករណីដែលសភាពការណ៍ជាក់ស្តែងតម្រូវ ។ | 2. The Licensee shall submit to EAC the copy of its audited financial statement not later than 3 months after the end of financial year to which they relate. The audit can be replaced by the control of EAC in the case that actual situation requires. |
| ៣- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្តល់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជានូវបណ្តាព័ត៌មានទាំងឡាយដែលអាជ្ញាធរទាមទារជាបន្តបន្ទាប់តាមបែបបទ និង ទំរង់កំណត់ដោយអាជ្ញាធរ ដើម្បីអាចឱ្យអាជ្ញាធរផ្ទៀងផ្ទាត់មើលការអនុវត្តន៍របស់អ្នកកាន់អាជ្ញាប័ណ្ណតាមល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ និង តាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងសេចក្តីសំរេចផ្សេងៗទៀត ។ | 3. The Licensee shall provide, in the manner and form determined by EAC, such information as EAC may require from time to time monitoring the Licensee's compliance with the conditions of this license, provision of the electricity law and any other legislative or regulatory requirements. |
| ៤- ដោយមិនគិតពីភាពទូទៅនៃវាក្យខ័ណ្ឌទី៣ អាជ្ញាធរអគ្គិសនីកម្ពុជាអាច | 4. Without prejudice to the generality of paragraph 3, EAC may |

ទាមទារឱ្យអ្នកកាន់អាជ្ញាប័ណ្ណផ្តល់នូវព័ត៌មានណាមួយ ឱ្យមានលក្ខណៈលំអិតខ្លាំងជាង ឬ ខុសពីការផ្តល់ព័ត៌មានធម្មតាដល់អាជ្ញាធរអគ្គិសនីកម្ពុជា ។

require the Licensee to supply information which is more extensive than or differs from that required to be prepared and supplied to EAC.

**លក្ខខណ្ឌទី៦ ៖ ភារកិច្ចបង់កម្រៃអាជ្ញាប័ណ្ណ**

**Condition 6: Obligation on Payment of License Fee**

១- ចាប់ពីថ្ងៃចូលជាធរមានរហូតដល់ថ្ងៃបញ្ចប់អាណត្តិ នៃអាជ្ញាប័ណ្ណនេះ អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវបង់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជានូវ "**កម្រៃអាជ្ញាប័ណ្ណប្រចាំខែ**" តាមអាត្រាកម្រៃអាជ្ញាប័ណ្ណ និងរូបមន្តគណនាកម្រៃអាជ្ញាប័ណ្ណ ដែលត្រូវកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា សំរាប់ឆ្នាំការិយបរិច្ឆេទនីមួយៗ ដោយអនុលោមតាមមាត្រា ២៧ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា ៣ នៃអនុក្រឹត្យស្តីពីការកំណត់កំរិតអតិបរមានៃកម្រៃអាជ្ញាប័ណ្ណសំរាប់អនុវត្ត ចំពោះអ្នកធ្វើសេវាកម្មអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

1. From the effective date to the end of the term of license, the Licensee shall pay to EAC "The Monthly License Fee" which is calculated according to the rate of license fee and the formula determined by EAC for each financial years pursuant to Article 27 of the Electricity Law of the Kingdom of Cambodia and Article 3 of Sub-Decree defining the maximum of License fee to be implemented to the electric power services in the Kingdom of Cambodia.

២- វិក្កយបត្រនៃកម្រៃអាជ្ញាប័ណ្ណប្រចាំខែ ត្រូវចាត់ទុកថាដំពាក់ និងត្រូវបង់ក្នុងរយៈពេល ១៤ថ្ងៃ បន្ទាប់ពីថ្ងៃដែលអ្នកកាន់អាជ្ញាប័ណ្ណបានទទួលវិក្កយបត្រ ។

2. Each invoice of monthly license fee shall be due and payable within 14 days after the day on which Licensee receives it.

**៣ លក្ខខណ្ឌសេវាកម្ម**

**3 SERVICE CONDITIONS**

**៣.១ លក្ខខណ្ឌទូទៅ**

**3.1 GENERAL CONDITIONS**

**លក្ខខណ្ឌទី៧ ៖ ការទំនាក់ទំនង**

**Condition 7: Communication**

១- រាល់ទំនាក់ទំនងទាំងអស់ពាក់ព័ន្ធជាមួយអាជ្ញាប័ណ្ណនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយយកភាសាខ្មែរជាគោល ។

1. All communications relating to this License shall be written in Khmer as an official.

**លក្ខខណ្ឌទី៨ ៖ លក្ខខណ្ឌពាក់ព័ន្ធនឹងផលប្រយោជន៍សាធារណៈ**

**Condition 8: Conditions on the Public Interest**

១- អ្នកកាន់អាជ្ញាប័ណ្ណ មិនត្រូវបោះបង់ចោលឬដិសេធចោលការគ្រប់គ្រងដំណើរការលើអចលនទ្រព្យអាជីវកម្មណាមួយ មុនពេលមានការឯកភាពពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។

1. The Licensee shall not dispose or relinquish operational control over any relevant asset prior the consent from EAC.

២- អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្តល់ឱ្យអាជ្ញាធរនូវសំណើជាលាយលក្ខណ៍អក្សរស្តីពីគោលបំណងរបស់គេក្នុងការបោះបង់ចោល ឬ បដិសេធចោលការគ្រប់គ្រងដំណើរការលើអចលនទ្រព្យអាជីវកម្មណាមួយ ដោយភ្ជាប់ជាមួយព័ត៌មានបន្ថែមផ្សេងៗទៀត តាមដែលអាជ្ញាធរស្នើសុំពាក់ព័ន្ធជាមួយនឹងអចលនទ្រព្យនោះ ឬ កាលៈទេសៈនៃការលះបង់ឬបដិសេធចោលការគ្រប់គ្រងនេះ ឬគោលបំណងនៃបុគ្គលណាមួយ ដែលចង់ទទួលយកឬទទួលគ្រប់គ្រងដំណើរការលើអចលនទ្រព្យនោះ ។

2. The Licensee shall give to EAC written proposal of its intention to dispose of or relinquish operational control over any relevant asset, together with such further information as EAC may request relating to such asset or the circumstances of such intended disposal or relinquishment of control or to the intentions in regard thereto of the person proposing to acquire such asset or operational control over such asset.

៣- អាជ្ញាធរអគ្គិសនីកម្ពុជា (បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយអ្នកកាន់អាជ្ញាប័ណ្ណ) អាចយល់ព្រមឬមិនយល់ព្រមនូវសំណើនេះ ។

3. EAC may (following consultation with the Licensee) consents or not consents to this proposal.

៤- អ្នកកាន់អាជ្ញាប័ណ្ណត្រូវពិគ្រោះយោបល់ជាមួយតំណាងបុគ្គលិក កម្មកររបស់ខ្លួន ដើម្បីបង្កើតឱ្យមានយន្តការឬវេទិកាជាប្រចាំមួយ សំរាប់រួមគ្នាពិគ្រោះពីបញ្ហារួមពាក់ព័ន្ធនឹងសុខភាព និងសុវត្ថិភាពរបស់ពួកគេ ។

4. The Licensee shall consult with appropriate representatives of persons employed by it in order to establish and maintain an appropriate machinery or forum for the joint consideration of matters of mutual concern in respect of the health and safety of such persons.

| | |
|---|---|
| ៥- នៅពេលមានការកំណត់ពីអាជ្ញាធរអគ្គិសនីកម្ពុជា ឱ្យអ្នកកាន់អាជ្ញាប័ណ្ណផ្គត់ផ្គង់ថាមពលអគ្គិសនី ក្នុងមួយថ្ងៃ ២៤ម៉ោង នោះ អ្នកកាន់អាជ្ញាប័ណ្ណត្រូវបំពេញតាមសំណូមពរនោះ ។ | 5. When the EAC obligates the licensee to supply electricity in 24 hours per day, licensee shall meet that obligation. |
| **លក្ខខណ្ឌទី៩ : លក្ខខណ្ឌចំពោះការធ្វើអាជីវកម្ម** | **Condition 9: Conditions on the Business** |
| ១- អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវប្រើប្រាស់អចលនទ្រព្យ នៃអាជីវកម្មរបស់អាជ្ញាប័ណ្ណនេះសំរាប់គោលបំណងអ្វីក្រៅពីការផលិត និងការចែកចាយ ដូចដែលបានកំណត់ក្នុងឯកសារនេះ ដោយគ្មានការអនុញ្ញាតជាមុនពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។ | 1. The Licensee shall not use the relevant assets of this License's business for the purpose other than Generation and Distribution as specified in this document without prior approval of EAC. |
| ២- អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវទទួលយក ឬចូលរួមជាមួយអាជីវកម្មអគ្គិសនីដទៃណាមួយទៀត ដែលមិនបញ្ជាក់ក្នុងអាជ្ញាប័ណ្ណ រួមទាំងអាជីវកម្មផលិតកម្ម បញ្ជូន ចែកចាយ ឬ លក់ថាមពលឡើយ ដោយគ្មានការអនុញ្ញាតជាមុនពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។ | 2. The Licensee shall not acquire or associate himself with any additional business, which is not identified in the license, including the business of generating, transmitting, distributing or supply of energy without an approval from EAC. |
| ៣- នៅគ្រប់ពេល អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវប្រគល់អាជ្ញាប័ណ្ណ ឬផ្ទេរការកាន់កាប់របស់ខ្លួន ឬផ្នែកណាមួយនៃអាជ្ញាប័ណ្ណដោយលក់ បញ្ចាំ ជួល ប្តូរឬ ផ្សេងពីនេះដោយគ្មានការអនុញ្ញាតពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។ | 3. The Licensee shall not, at any time, assign his License or transfer his undertaking, or any part thereof, by sale, mortgage, lease, exchange or otherwise, unless approved by EAC. |
| ៤- កិច្ចព្រមព្រៀងណាមួយពាក់ព័ន្ធជាមួយកិច្ចការ ដែលបានអធិប្បាយក្នុងវាក្យខ័ណ្ឌទី១, ទី២ និងទី៣ ខាងលើ បើពុំមានការឯកភាពជាលាយល័ក្ខណ៍អក្សរជាមុនពីអាជ្ញាធរអគ្គិសនីកម្ពុជាទេ ត្រូវចាត់ទុកជាមោឃៈ និងត្រូវចាត់ទុកជាការរំលោភលើល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណ ។ | 4. Any agreement relating to any transaction of the nature described above at paragraph 1, 2 and 3 unless made with the prior written consent of EAC, shall be void and will constitute violation of Conditions of License. |
| ៥- អ្នកកាន់អាជ្ញាប័ណ្ណត្រូវដំណើរការ និងគ្រប់គ្រងសេវាកម្មអគ្គិសនីដែលបានផ្តល់ដោយអាជ្ញាប័ណ្ណនេះឱ្យមានប្រសិទ្ធភាព គុណភាព និងតម្លាភាព ដោយអនុលោមតាមល័ក្ខខ័ណ្ឌកំណត់ក្នុងអាជ្ញាប័ណ្ណនេះ និងបទបញ្ញត្តិដែលកំណត់ក្នុងវិធាននានារបស់អាជ្ញាធរអគ្គិសនីកម្ពុជា ។ | 5. The Licensee shall operate and manage the Services provided by this License in an efficient, quality and transparent manner in accordance with the requirement of this License and the regulations defined in the Rules issued by EAC. |
| ៦- អ្នកកាន់អាជ្ញាប័ណ្ណត្រូវពង្រីក និងកែលំអមធ្យោបាយធ្វើសេវាកម្មរបស់ខ្លួនតាមកម្មវិធីដែលបានការយល់ព្រមពីអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីធានាការផ្គត់ផ្គង់អគ្គិសនីដល់គ្រប់អ្នកប្រើប្រាស់ក្នុងតំបន់ ។ | 6. The Licensee shall extend and improve its facilities in accordance with its plan approved by EAC to ensure the electricity supply to all consumers in the area. |
| ៧- ក្នុងរយៈពេល ៦ខែបន្ទាប់ពីបានទទួលអាជ្ញាប័ណ្ណនេះ អ្នកកាន់អាជ្ញាប័ណ្ណត្រូវរកសាងថ្លៃដើមអគ្គិសនី និងស្នើសុំអាជ្ញាធរអគ្គិសនីកម្ពុជា អនុម័តលើបញ្ជីថ្លៃលក់អគ្គិសនី ដើម្បីអនុវត្តក្នុងតំបន់ចែកចាយរបស់ខ្លួន ។ មុនពេលអាជ្ញាធរអគ្គិសនីកម្ពុជា អនុម័តលើបញ្ជីថ្លៃលក់អគ្គិសនី អ្នកកាន់អាជ្ញាប័ណ្ណ អាចបន្តលក់អគ្គិសនីតាមថ្លៃលក់ចាស់ ដែលក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឬស្ថាប័នតំណាង បានអនុម័តពីមុន ។ | 7. Within 6 months after receiving this license, the licensee shall prepare the cost of electricity and request EAC approval on the tariff to implement in its distribution area. Before EAC's approval on new tariff, the licensee can use the existing electricity tariff approved by Ministry of Industry, Mines and Energy or Representative Institution. |
| **លក្ខខណ្ឌទី១០ : លក្ខខណ្ឌលក់មធ្យោបាយធ្វើសេវាកម្ម ក្នុងករណីមានការតម្រូវពីអាជ្ញាធរអគ្គិសនីកម្ពុជា** | **Condition 10: Sale Condition of Service Facilities in the case it is required from EAC** |
| ១- ក្នុងរយៈពេល៦ខែ បន្ទាប់ពីបានទទួលអាជ្ញាប័ណ្ណនេះ អ្នកកាន់អាជ្ញាប័ណ្ណត្រូវស្នើសុំអាជ្ញាធរអគ្គិសនីកម្ពុជា អនុម័តនិងចុះបញ្ជីអចលនទ្រព្យសំរាប់ធ្វើសេវាកម្មរបស់ខ្លួន ។ បញ្ជីនេះ ត្រូវបញ្ជាក់លំអិតនៅឆ្នាំចាប់ផ្តើម | 1. Within six months after receiving this license, the licensee shall submit the list of its facilities for approval and registering at EAC as relevant asset. The list should also give details on year of |

ដំណើរការអាជីវកម្ម និងតំលៃដើមនៃមធ្យោបាយធ្វើសេវាកម្មនីមួយៗ ។ បន្ទាប់ពីនោះ សំរាប់ឆ្នាំនិមួយៗនៅមុនថ្ងៃទី១៥ ខែកុម្ភៈ អ្នកកាន់អាជ្ញាប័ណ្ណត្រូវស្នើសុំអាជ្ញាធរអគ្គិសនីកម្ពុជា កែសំរួលបញ្ជីមធ្យោបាយធ្វើសេវាកម្មរបស់ខ្លួនដែលមានជាក់ស្តែងដល់ថ្ងៃទី៣១ ខែធ្នូ កន្លងមក។ បញ្ជីនេះត្រូវបង្ហាញនូវមធ្យោបាយធ្វើសេវាកម្មដែលមានពីដើមឆ្នាំ ដែលបានបន្ថែមឬលុបចេញក្នុងឆ្នាំ ដោយមានបញ្ជាក់តំលៃមធ្យោបាយធ្វើសេវាកម្មនោះ និងមធ្យោបាយធ្វើសេវាកម្មដែលមាននៅចុងឆ្នាំ ។

២- ស្របតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹតនានា ក្នុងករណីដកហូតអាជ្ញាប័ណ្ណ អាជ្ញាធរអគ្គិសនីកម្ពុជា អាចតំរូវឱ្យអ្នកកាន់អាជ្ញាប័ណ្ណ លក់ឬផ្ទេរមធ្យោបាយធ្វើសេវាកម្មដែលបានចុះបញ្ជីនៅអាជ្ញាធរអគ្គិសនីកម្ពុជា ឱ្យអ្នកបន្តវេនមួយផ្សេងទៀត តាមគោលការណ៍ហិរញ្ញវត្ថុ ដែលកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។

## ៣.២ លក្ខខណ្ឌសេវាកម្មផលិតកម្ម

### លក្ខខណ្ឌទី១១ : លក្ខខណ្ឌចំពោះមធ្យោបាយផលិតកម្ម

១- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ បើសិនជាអ្នកកាន់អាជ្ញាប័ណ្ណមានបំណងបន្ថែមមធ្យោបាយផលិតកម្មថ្មីថែមទៀត ពេលនោះត្រូវស្នើសុំការអនុញ្ញាតពីអាជ្ញាធរអគ្គិសនី ចំពោះមធ្យោបាយផលិតកម្មថ្មីនីមួយៗ ។

២- មធ្យោបាយផលិតកម្មដែលមានស្រាប់របស់អ្នកកាន់អាជ្ញាប័ណ្ណមានបញ្ជាក់ក្នុងឧបសម្ព័ន្ធទី២ ។

៣- ក្នុងករណីដែលអ្នកកាន់អាជ្ញាប័ណ្ណ បានទទួលសិទ្ធិធ្វើសេវាកម្មលើមធ្យោបាយផលិតកម្មបន្ថែមទៀតតាមខ្លឹមសារប្រការ១ នៃផ្នែកទី១របស់អាជ្ញាប័ណ្ណ ឧបសម្ព័ន្ធទី២នៃអាជ្ញាប័ណ្ណត្រូវធ្វើការកែសំរួលជាថ្មី ។

### លក្ខខណ្ឌទី១២ : លក្ខខណ្ឌចំពោះកិច្ចដំណើរការប្រព័ន្ធផលិតកម្ម

១- អ្នកកាន់អាជ្ញាប័ណ្ណត្រូវធ្វើផែនការ និងអភិវឌ្ឍផ្នែកនីមួយៗនៃប្រព័ន្ធផលិតកម្មរបស់ខ្លួន ដើម្បីឱ្យកិច្ចដំណើរការផលិតកម្មមានប្រសិទ្ធភាព ស្ថេរភាព និងគុណភាព ។

២- អ្នកកាន់អាជ្ញាប័ណ្ណត្រូវរៀបចំ និងជូនព័ត៌មានឱ្យអាជ្ញាធរអគ្គិសនីកម្ពុជាឱ្យបានដឹងនូវផែនការសកម្មភាពដែលអ្នកកាន់អាជ្ញាប័ណ្ណត្រូវអនុវត្ត ដើម្បីឱ្យកិច្ចដំណើរការផលិតកម្មមានប្រសិទ្ធភាព ស្ថេរភាពនិងគុណភាព ។

## ៣.៣ លក្ខខណ្ឌសេវាកម្មចែកចាយ

### លក្ខខណ្ឌទី១៣ : លក្ខខណ្ឌចំពោះតំបន់ធ្វើសេវាកម្ម

១- អាជ្ញាប័ណ្ណនេះផ្តល់សិទ្ធិឱ្យអ្នកកាន់អាជ្ញាប័ណ្ណ ធ្វើសេវាកម្មចែកចាយអគ្គិសនីនៅភូមិបាក់ខែង និងភូមិខ្ទរ សង្កាត់ព្រែកលៀប ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដែលមានកំណត់ព្រំដែនច្បាស់លាស់ក្នុងឧបសម្ព័ន្ធទី១ នៃអាជ្ញាប័ណ្ណនេះ។

២- អ្នកប្រើប្រាស់ធំៗ និងអ្នកប្រើប្រាស់ដុំក្នុងតំបន់ចែកចាយខាងលើ អាច

commissioning and the original cost of each facility. Thereafter, for revision of the list of relevant asset, the licensee shall submit to EAC by 15th February each year, the list of its facilities as on 31st December of the previous year. The list should indicate the facilities in the beginning of the year, additions made during the year with its cost, deletion made during the year with its original cost and facilities at the end of the year.

2. Under Electricity Law and Sub-decrees, in the case of revocation of license, EAC can require licensee to sale or transfer its facilities registered with EAC to the successor in accordance with financial principle determined by EAC.

## 3.2 CONDITIONS ON GENERATION SERVICE

### Condition 11: Conditions on the Generation Facilities

1. Under this license, if the licensee intends to add new generation facilities, then he must ask for permission from EAC for each new generation facility.

2. The existing generation facilities of the Licensee are specified in Schedule 2.

3. In case the Licensee received the right to do the business on the additional power generation facilities, Article 1 of part 1 of the license, and schedule 2 of license shall be revised accordingly.

### Condition 12: Conditions on the Generation System Operation

1. The Licensee shall plan and develop each part of its generation system, such that the generation operation can be performed efficiently, sustainably and qualitatively.

2. The Licensee shall draw up and inform to EAC the action plan by which the Licensee shall perform to provide the efficient, sustainable and quality generation services.

## 3.3 CONDITIONS ON DISTRIBUTION SERVICE

### Condition 13: Conditions on Electric Power Service Area

1. This license provides the right to licensee to distribute electric power in Phum Bak Kheng and Phum Ktor, Sangkat Prek Lep, Khan Rusey Keo, Phnom Penh, as clearly indicated the location in schedule 1 of this license.

2. Big consumers and bulk consumers in the above distribution area

មានសិទ្ធិជ្រើសរើសប្រភពផ្គត់ផ្គង់ពីប្រព័ន្ធបញ្ជូន ឬពីប្រព័ន្ធចែកចាយមេផ្សេងទៀតបាន បើសិនជាមានការយល់ព្រមពីអាជ្ញាធរអគ្គិសនីកម្ពុជា ។

may have the right to select other supply sources from the transmission line or main distribution network if they have the approval from EAC.

**លក្ខខណ្ឌទី១៤ : លក្ខខណ្ឌចំពោះមធ្យោបាយធ្វើសេវាកម្ម**

**Condition 14: Conditions on Electric Power Service Facilities**

១- អ្នកកាន់អាជ្ញាប័ណ្ណ មានកាតព្វកិច្ចអភិវឌ្ឍន៍មធ្យោបាយធ្វើសេវាកម្មរបស់ខ្លួន ដើម្បីអាចផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់របស់ខ្លួនបាន និងប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព ។ ការធ្វើផែនការ និងការអភិវឌ្ឍន៍ប្រព័ន្ធចែកចាយ អ្នកកាន់អាជ្ញាប័ណ្ណត្រូវគោរពតាមស្តង់ដាដែលចេញដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ប្រសិនបើមិនទាន់មានស្តង់ដាដែលចេញដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អ្នកកាន់អាជ្ញាប័ណ្ណត្រូវអនុវត្តតាមស្តង់ដារ ដែលអាចរក្សាបាននូវលទ្ធភាព សន្តិសុខ និងគុណភាពនៃសេវារបស់ប្រព័ន្ធចែកចាយ ដែលបានទទួលការយល់ព្រមពីអាជ្ញាធរអគ្គិសនីកម្ពុជា ។

1. The licensee shall have the obligation to develop its distribution system in order to supply the electricity to its consumers with efficiency and security. To perform the plan and develop of the distribution system, licensee shall be respected to standards issuing by Ministry of Industry, Mines and Energy. If standard are not yet issuing by Ministry of Industry, Mines and Energy, the licensee shall follow such other standard to maintain the availability, safety and quality of service as approved by EAC.

**លក្ខខណ្ឌទី១៥ : លក្ខខណ្ឌចំពោះកិច្ចដំណើរការប្រព័ន្ធចែកចាយ**

**Condition 15: Conditions on Distribution System Operation**

១- អ្នកកាន់អាជ្ញាប័ណ្ណត្រូវដំណើរការការផ្គត់ផ្គង់ និង ការចែកចាយរបស់ខ្លួនតាមស្តង់ដាប្រតិបត្តិមួយ ដែលកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា អនុលោមតាមមាត្រា ៣ និង ៧(ង) របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។

២- អ្នកកាន់អាជ្ញាប័ណ្ណត្រូវរៀបចំឱ្យមានប្រភពអគ្គិសនីគ្រប់គ្រាន់មួយ សំរាប់ផ្គត់ផ្គង់ឱ្យអតិថិជនរបស់ខ្លួន ។ អ្នកកាន់អាជ្ញាប័ណ្ណត្រូវធានានូវល័ក្ខខ័ណ្ឌដូចខាងក្រោម :

(ក) មិនត្រូវមានការកាត់ផ្តាច់លើសពីរយៈពេលស្តង់ដា ដែលបានអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា និង

(ខ) តង់ស្យុង និងហ្វ្រេកង់អគ្គិសនី មិនត្រូវហួសពីកំរិតព្រំដែនដំណើរការជាធម្មតាដែលអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។

៣- អ្នកកាន់អាជ្ញាប័ណ្ណត្រូវគោរពតាមកូដប្រព័ន្ធចែកចាយមួយ ដែលអាជ្ញាធរអគ្គិសនីកម្ពុជានឹងកំណត់នៅពេលក្រោយ ។

1. The Licensee shall conduct its Supply and Distribution Operation in accordance with standards of performance determined by EAC pursuant to Article 3 and 7(e) of the Electricity Law of the Kingdom of Cambodia.

2. The Licensee shall ensure availability of sufficient power sources for supply to its consumers. Licensee shall ensure the following conditions:

   (a) Supply of electricity may not be discontinued for more than the time limit approved by EAC; and

   (b) the voltage or frequency of electricity may not vary beyond the permissible operational limits approved by EAC.

3. The Licensee shall comply with the Distribution Code approved by EAC.

**លក្ខខណ្ឌទី១៦ : លក្ខខណ្ឌចំពោះការផ្គត់ផ្គង់អគ្គិសនីឱ្យអតិថិជន**

**Condition 16: Conditions on Electric Power Supply to Customers**

១- អ្នកកាន់អាជ្ញាប័ណ្ណត្រូវគោរពតាមបទប្បញ្ញត្តិរបស់អាជ្ញាធរអគ្គិសនីកម្ពុជាស្តីពីល័ក្ខខ័ណ្ឌទូទៅក្នុងការផ្គត់ផ្គង់អគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- ក្នុងការចែកចាយអគ្គិសនី អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវរើសអើងរវាងបុគ្គលឬក្រុមបុគ្គលណាមួយជាមួយបុគ្គលឬក្រុមបុគ្គលណាមួយទៀតឡើយ ។

1. The Licensee shall comply with the EAC's Regulations on general conditions of supply of electricity in the Kingdom of Cambodia.

2. In the provision of electricity, the Licensee shall not discriminate between persons or classes of persons.

# ឧបសម្ព័ន្ធទី១

# តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី

# SCHEDULE 1

# AUTHORIZED DISTRIBUTING AREA

| | |
|---|---|
| ១- តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី ដែលអ្នកកាន់អាជ្ញាប័ណ្ណ មានសិទ្ធិផ្តល់សេវាចែកចាយ និងផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់ គឺនៅភូមិបាក់ខែង និងភូមិខ្ទរ សង្កាត់ព្រែកលៀប ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។ | 1. The authorized distribution area, where the licensee has the right to provide the electricity and supply service to consumers is Phum Bak Kheng and Phum Ktor, Sangkat Prek Lep, Khan Rusey Keo, Phnom Penh. |
| ២- តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនីនេះ កំណត់ដោយ "ផែនទីកំណត់ព្រំប្រទល់ " ដែលភ្ជាប់មកជាមួយ ។ | 2. This authorized distribution area is determined by “the boundary map” attached. |

# ឧបសម្ព័ន្ធទី២
# មធ្យោបាយផលិតកម្មដែលមានស្រាប់របស់អ្នកកាន់អាជ្ញាប័ណ្ណ

## SCHEDULE 2
## EXISTING GENERATING FACILITIES OF THE LICENSEE

| | |
|---|---|
| **ក-មធ្យោបាយផលិតកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណ** | **A. Licensee's Generation Facilities** |
| **រោងម៉ាស៊ីន** | **Licensee's Generator House** |
| ១- រោងម៉ាស៊ីនរបស់អ្នកកាន់អាជ្ញាប័ណ្ណ ស្ថិតក្នុងភូមិបាក់ខែង សង្កាត់ព្រែកលៀប ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។ | 1. The licensee's generator house is located at Phum Bak Kheng, Sangkat Prek Lep, Khan Rusey Keo, Phnom Penh. |
| **លក្ខណៈទូទៅនៃម៉ាស៊ីន** | **General Specifications of the Generators** |
| ១- អ្នកកាន់អាជ្ញាប័ណ្ណ មានម៉ាស៊ីនភ្លើងចំនួន ០១គ្រឿង ដែលមានអានុភាពតម្លើង 100kVA | 1. The licensee has 01 unit of generators with the installed capacity of 100 kVA. |
| ២- ម៉ាស៊ីនភ្លើងខាងលើ ប្រើប្រាស់ប្រេងម៉ាស៊ូត ។ | The normal fuel for the generators is Diesel Oil (DO). |

# ឧបសម្ព័ន្ធទី៣
# លក្ខខ័ណ្ឌសំរាប់ធ្វើការដកហូតអាជ្ញាប័ណ្ណ
## SCHEDULE 3
## TERM OF REVOCATION

| | |
|---|---|
| ១- អាជ្ញាធរអគ្គិសនីកម្ពុជាអាចធ្វើការដកហូតអាជ្ញាប័ណ្ណ ដែលបានផ្តល់ដោយឯកសារនេះបានគ្រប់ពេលតាមកាលៈទេសៈ ដូចខាងក្រោម ៖ | 1. EAC may at any time consider revocation of license granted by this Document under following circumstance: |
| (ក) ប្រសិនបើ អ្នកកាន់អាជ្ញាប័ណ្ណសំណូមពរជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរអគ្គិសនីកម្ពុជាសុំឱ្យដកហូតអាជ្ញាប័ណ្ណនេះ ។ | (a) if the Licensee requests in writing to EAC that that such license may be revoked; |
| (ខ) ប្រសិនបើ ចំនួនទឹកប្រាក់ដែលត្រូវបង់ណាមួយតាមល័ក្ខខ័ណ្ឌទី៦ទាក់ទងជាមួយអាជ្ញាប័ណ្ណនេះ មិនបានទូទាត់ក្នុងរយៈពេល ១៥ថ្ងៃ ក្រោយថ្ងៃ ដែលកំណត់ឱ្យបង់ ឬ មិនបានទូទាត់ក្នុងរយៈពេល ១៤ថ្ងៃ បន្ទាប់ពីថ្ងៃដែលអាជ្ញាធរអគ្គិសនីកម្ពុជាបានប្រគល់លិខិតជូនដំណឹងឱ្យទៅអ្នកកាន់អាជ្ញាប័ណ្ណថា ថ្ងៃទូទាត់បានផុតកំណត់ហើយ ប៉ុន្តែលិខិតជូនដំណឹងនេះមិនត្រូវចេញមុន ដែល ចំនួនទឹកប្រាក់នេះត្រូវកំណត់ឱ្យបង់ឡើយ ។ | (b) if any amount payable under Condition 6 in relation to this license is unpaid 15 days after it has become due or remains unpaid for a period of 14 days after EAC has given the Licensee notice that the payment is overdue provided that no such notice shall be given earlier than the day on which the amount payable became due; |
| (គ) ប្រសិនបើ តាមយោបល់របស់អាជ្ញាធរអគ្គិសនីកម្ពុជាអ្នកកាន់អាជ្ញាប័ណ្ណ បានប្រព្រឹត្តិខុសពីល័ក្ខខ័ណ្ឌណាមួយនៃអាជ្ញាប័ណ្ណ និងមិនគោរពតាមបទបញ្ជាចុងក្រោយរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ក្នុងការកែតម្រូវកំហុសនេះ ឬ | © if the Licensee in the opinion of the EAC has committed a material breach of any of the terms and Conditions of such License and does not comply with a final order of EAC to rectify such breach; or |
| (ឃ) ប្រសិនបើ តាមយោបល់របស់អាជ្ញាធរអគ្គិសនីកម្ពុជា អ្នកកាន់អាជ្ញាប័ណ្ណមិនបានបំពេញភារៈកិច្ច និង កាតព្វកិច្ចដែលបានកំណត់ដោយអាជ្ញាប័ណ្ណនេះឱ្យបានពេញលេញ និងប្រកបដោយប្រសិទ្ធភាព ឬ | (d) if the Licensee in the opinion of the EAC, is not in a position to fully and efficiently discharge the duties and obligations imposed on Licensee by such License; or |
| (ង) ប្រសិនបើ តាមយោបល់របស់អាជ្ញាធរអគ្គិសនីកម្ពុជា អ្នកកាន់អាជ្ញាប័ណ្ណបានប្រព្រឹត្តិខុសដោយចេតនា និង គ្មានហេតុផលចំពោះបទប្បញ្ញត្តិ និងល័ក្ខខ័ណ្ឌដែលកំណត់ក្នុងវិធាន និងបទប្បញ្ញត្តិ ដែលសំរេចដោយអាជ្ញាធរអគ្គិសនីកម្ពុជា និងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា រួមទាំងច្បាប់ស្តីពីការការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ សុវត្ថិភាព សុខភាព ពន្ធដារ ព្រមទាំងការអនុវត្តន៏ការការពារ និងស្តង់ដានៃប្រព័ន្ធអគ្គិសនី ។ | (e) if in the opinion of EAC the Licensee has committed a willful or unreasonable default to comply with conditions set forth in the rules and regulations adopted by EAC, and the Laws of the Kingdom of Cambodia, including Laws regarding environmental protection, natural source, safety, health, taxes, and electric system performance, protection and standards; |
| ២- នៅគ្រប់ពេល អាជ្ញាធរអគ្គិសនីកម្ពុជាអាចចេញសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដោយទុករយៈពេលមិនតិចជាង ៣ខែ ទៅអ្នកកាន់អាជ្ញាប័ណ្ណស្តីពីមូលហេតុ ដែលឈរលើនេះអាជ្ញាប័ណ្ណណាមួយតម្រូវឱ្យដកហូត ។ | 2. EAC may at any time give not less than 3 months notice in writing to the Licensee stating the grounds on which any License is proposed to be revoked. |
| ៣- ជំនួសឱ្យការដកហូតអាជ្ញាប័ណ្ណ អាជ្ញាធរអគ្គិសនីកម្ពុជាអាចអនុញ្ញាតឱ្យអាជ្ញាប័ណ្ណនេះបន្តនៅជាធរមានបន្តទៀត បើសិនជាមានល័ក្ខខ័ណ្ឌបន្ថែមទៀតដែលយល់ថាគួរត្រូវដាក់ជំនួស រួចល័ក្ខខ័ណ្ឌបន្ថែមដែលត្រូវដាក់នេះត្រូវចងភ្ជាប់តាមផ្លូវច្បាប់ និងត្រូវប្រតិបត្តិតាមដោយអ្នកកាន់អាជ្ញា-ប័ណ្ណ និងត្រូវចូលជាធរមានដូចបានកំណត់ក្នុងអាជ្ញាប័ណ្ណដូច្នេះដែរ ។ | 3. EAC may, instead of revoking any License, permit it to remain in force subject to such further terms and conditions as considered fit to impose and any further terms or conditions imposed shall be binding upon and be observed by the Licensee, and be of like force and effect as if they were contained in the License. |